ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី១ ឆ្នាំ២០២១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

www.ecosocc.gov.kh

info@ecosocc.kh

(855) 012 915 577 (855) 012 912 009

# គតិបណ្ឌិតរដ្ឋបុរសជាតិ

**« កាលពីក្នុងពេលមានសង្គ្រាមប្រឈមមុខគ្នា**
**យើងធ្លាប់ប្រើយុទ្ធវិធីយកសមរភូមិយោធាដើម្បីសង្កត់តុចរចា**
**តែក្នុងពេលបច្ចុប្បន្នដែលប្រទេសយើងមានសន្តិភាព**
**យើងយកការអភិវឌ្ឍដើម្បីកាត់បន្ថយភាពក្រីក្រ**
**អ្នកឈ្នះតែមួយគត់ គឺប្រជាពលរដ្ឋកម្ពុជា។ »**

**សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
ថ្ងៃទី០៩ មីនា ២០០៦

**ក្រុមការងារព្រឹត្តិបត្រ**

**នាយកគ្រប់គ្រង**

- យឹម ណុលសន

**និពន្ធនាយក**

- អ៊ីវ ចុង

**ការិយាល័យនិពន្ធ**

- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

**អ្នកចាត់ចែងផលិត**

- ប៉ិច សុខា
- អ៊ិន តុលា

**អ្នកចែកផ្សាយ**

- អៀង រដ្ឋា
- សេក វុទ្ធី

**ការីកុំព្យូទ័រ**

- អេង រត្នមុនី
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**


I- បទអត្ថាធិប្បាយ " វប្បធម៌ជាតិ ( Culture nationale ) " ១-៩

II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តៈ

១- ច្បាប់ស្តីពីការប្រកួតប្រជែង ១០

២- សេចក្តីព្រាងស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៨០ អនក្រ.បក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងដាក់ស្លាកសញ្ញាសារធាតុគីមី ១១

III- បទវិភាគៈ

- រដ្ឋមន្ត្រីការបរទេសចិនលោក Wang Yi ១២-១៣

IV- ការសិក្សា

- ការវិវត្តនៃប្រព័ន្ធទឹកសាប និងប្រវត្តិនៃវិស័យជលផលទឹកសាបកម្ពុជា ( ត ) ១៤-២៣

V- នាទីវប្បធម៌

- ពន្យល់ពាក្យ " បត់ " ២៤-២៥

- ស្វែងយល់អំពីពាក្យ សុភាសិត ២៦-២៩

VI- នាទីកំណាព្យ

- ឱដួងច័ន្ទ ( បទពាក្យ៩ ) ៣០

- អ្នកប្រុស្រ ( បទពាក្យ៧ ) ៣០

VII- នាទីកំសាន្ត

- រឿងសត្វរើសគ្នាធ្វើជាស្តេច ៣១

# វប្បធម៌ជាតិ

( Culture nationale )

ខ្លះថាវប្បធម៌គឺអ្វីៗដែលទាក់នឹងការសិក្សានិងអប់រំ។ ខ្លះថាជាការសិក្សាពង្រីកវិជ្ជា។ អ្នកប្រាជ្ញអាល្លឺម៉ង់ថា វប្បធម៌គឺអ្វីៗដែលឱ្យមានការចម្រើនលូតលាស់គ្រប់វិស័យ។ រួមសេចក្ដីមក វប្បធម៌សំដៅយកធម៌ទាំងឡាយណាដែលធ្វើឱ្យមានការលូតលាស់ ចម្រុងចម្រើនក្នុងសង្គម ដោយការសិក្សាអប់រំនិងអនុវត្តន៍។ វប្បធម៌មានសមាសធាតុៈ អក្សរសិល្ប៍ សិល្បៈសាស្ត្រ (កុន ល្ខោន គំនូរ) សាសនា សារពត៌មាន ទស្សនាវដ្ដី វិទ្យុ ទូរទស្សន៍ កីឡា ល្បែង...។ វប្បធម៌ជាការផ្សាយពុទ្ធិ ឯសង្គមធម៌ជាអង្គការសម្រាប់អនុវត្តឱ្យបានចម្រើនលូតលាស់ ទើបប្រទេសជាតិជួបប្រទះអរិយធម៌។

អក្សរសិល្ប៍ជាផ្នែកមួយនៃវប្បធម៌ ហើយអក្សរសិល្ប៍ក៏ជាផ្លែផ្កានៃរបបមួយ។ អ្នកនិពន្ធ ខឹម សំឌី ក្នុងស្នាដៃ«ប្រវត្តិអក្សរសាស្ត្រខ្មែរ»បោះផ្សាយនៅឆ្នាំ១៩៦០ បានឱ្យយើងដឹងថា នៅក្រោមនឹមដែកចក្រពត្រអាណានិគមនិយមជាង១០០ឆ្នាំកន្លងទៅហើយ ប្រជាជនយើងស្រីប្រុសត្រូវឃ្លាតចេញឆ្ងាយពីវប្បធម៌ជាតិ ពីប្រវត្តិសាស្ត្រជាតិ ត្រូវពួកអាណានិគមនិយមបារាំងបង្ខំឱ្យរៀនភាសាគេ ឱ្យទទួលប្រើអក្សរគេជាផ្លូវការ ឱ្យក្រេបជញ្ជក់នូវវប្បធម៌ចក្រពត្តិ និយមពុករលួយ។ ដូចនេះហើយបានជាយើងច្រើនមានគុណវិបត្តិអណ្ដែតអណ្ដូងវិលតាមគេ មាក់ងាយភ្លេចកេរ្ដិ៍ដំណែលស្នាដៃប្រជាជនខ្មែរយើងមាន សិល្បៈ អក្សរសាស្ត្រជាដើម។

ដើម្បីជាប្រយោជន៍ដល់ជនរួមជាតិគ្រប់ជាន់ថ្នាក់ យើងបានខិតខំបង្កើនសៀវភៅសិក្សាពិចារណា ក្នុងបំណងបំផុសស្មារតីអំណានឲ្យបានផុលផុស ដែលជាវិភាគទានដ៏សំខាន់ដល់ការអភិរក្ស និងអភិវឌ្ឍប្រទេសជាតិ។ អ្នកនិពន្ធដដែលបានវែកញែកទំនាក់ទំនងសង្គម និងអក្សរសិល្ប៍ថា ក្នុងសង្គមសក្តិភូមិ អក្សរសិល្ប៍ក៏សក្តិភូមិដែរ។ អត្ថរសអក្សរសិល្ប៍ទាំងនោះច្រើនផ្អែកលើសាសនា ច្រើនផ្អែកលើបុគ្គលមួយរូប ដែលគេច្រើនលើកតម្កើងជាតំណាង «អាទិទេព» តំណាង «ព្រះម្ចាស់សួគ៌» តំណាង«ព្រះពោធិសត្វ»...។ គេច្រើនរាប់ថាបុគ្គលនោះ គឺជាពូជជាន់ខ្ពស់ចុះពីឋានលើមកយកកំណើត ហើយត្រូវមានឥទ្ធិពលបង្ក្រាបជិះជាន់គេបានតាមចិត្ត បាញ់សម្លាប់បានទាំងអស់ គ្មានច្បាប់ឯណាធំជាងបុគ្គលមួយរូបនោះទេ។ គេនិយាយដូច្នោះ ដើម្បីបោកប្រាស់ប្រជាជនឱ្យសុខចិត្តគោរពកោតខ្លាច ទុកខ្លួនដូចសត្វតិរច្ឆាន។

ក្នុងសង្គមមូលធននិយមអក្សរសិល្ប៍ក៏មានលក្ខណៈមូលធនដែរ។ គេច្រើនបង្វិលប្រជាជនឱ្យអណ្ដែតអណ្ដូងយល់ឃើញថា«លោកតាប្រាក់ធំជាងគេ»។ជីវិតមនុស្សត្រូវតែរស់ដើម្បីលុយ។ គេបង្កើតនិងបណ្ដុះគំនិតដូចនេះ ព្រោះគេឱ្យប្រជាជនខ្លាចនាយទុន សុខចិត្តឱ្យគេប្រើរហូតទៅ ហើយឱ្យយល់ថាមានតែលុយ និងនាយទុនទេ ដែលជាអ្នកមានមហិទ្ធិឫទ្ធិ ជាម្ចាស់ធនធានក្នុងសង្គមទាំងអស់។

ក្នុងសង្គមចម្រើនជឿនលឿន អក្សរសិល្ប៍ក៏ចម្រើនជឿនលឿនដែរ។ អក្សរសិល្ប៍ចម្រើនជឿនលឿនមានចរិតប្រជាជាតិ ប្រជាជន និងវិទ្យាសាស្ត្រ មានន័យថា ដឹកនាំប្រជាជនឱ្យស្គាល់កម្លាំងរបស់ខ្លួន ឱ្យលះបង់ចោលនូវជំនឿគ្មានសមហេតុសមផល។ ចង់បានទឹកធ្វើស្រែ ពុំត្រូវបន់ស្រន់ទេវតាឡើយ ត្រូវជីកព្រែក ជីកប្រឡាយ ស្រះ ត្រពាំង លើកទំនប់...។ អក្សរសិល្ប៍ចម្រើនជឿនលឿនផ្អែកទៅលើវិទ្យាសាស្ត្រ ដែលអាចបំភ្លឺមនុស្សឲ្យឃើញការពិតជាក់ស្ដែង និងអាចជួយសម្រាលកម្លាំងមនុស្សក្នុងការបង្កើតផលិតផល។ ប្រសិនបើយើងងាកមើលក្រោយបន្តិចតាមរយៈប្រវត្តិសាស្ត្រយើងក៏ឃើញវិវត្តន៍អក្សរសិល្ប៍ទៅតាមទស្សនៈខាងលើនេះដែរ។

-អក្សរសិល្ប៍សម័យអង្គរ មានការលូតលាស់សម្បើមណាស់ តែមានលក្ខណៈជាអក្សរសិល្ប៍វណ្ណៈស្រទាប់លើ។

-អក្សរសិល្ប៍ក្រោយសម័យអង្គរ ចែកចេញជាចង្កោមពីរ។ មួយ អក្សរសិល្ប៍ផ្សាយដោយកវីចំណានៗ ដែលច្រើនទទួលការឧបត្ថម្ភពីក្រុងលង្វែកនិងក្រុងឧដុង្គ។អក្សរសិល្ប៍ផ្នែកនេះបម្រើវណ្ណៈខ្លាំងពូកែនិងការពារវណ្ណៈនោះ។ ពីរ អក្សរសិល្ប៍ប្រជាប្រិយ ដែលផុសចេញមកពីមាត់ប្រជាជន។ អក្សរសិល្ប៍នេះពុំបានចងក្រងជាសាស្ត្រាជាក់លាក់ទេ ហើយគេច្រើនឲ្យឈ្មោះថាជារឿងព្រេង។

-នៅសម័យអាណានិគម ពួកវាបានប្រើមធ្យោបាយឧក្រិដ្ឋជាច្រើន ដើម្បីបំបាត់អក្សរសិល្ប៍ខ្មែរយើង។ វាបង្រៀនកូនខ្មែរឲ្យចេះខ្ពើមវប្បធម៌ជាតិខ្លួន កលល្បិចវាមានច្រើនៈ

១.បង្កើតសាលាបារាំងដើម្បីបង្ហាត់បង្រៀនកូនខ្មែរឲ្យធ្វើជើងឈ្នួលបន្តដៃពួកអាណានិគមនិយមបារាំង។ វាសង់គុកច្រើនជាងសង់សាលា។ ប្រជាជនបួនលាននាក់មានវិទ្យាល័យតែមួយ។

(...) ក្នុងកំឡុងប៉ែតសិបឆ្នាំកូនខ្មែរដែលបានរៀនភាសាបារាំង ឈប់ស្គាល់អរិយធម៌ វប្បធម៌ខ្មែរ ហើយថែមទាំងអណ្តែតអណ្តូងទៅតាមរយៈការឃោសនារបស់វា ជឿថាខ្មែរគ្មានវប្បធម៌ គ្មានអក្សរសិល្ប៍ផង។អរិយធម៌ដែលអាណានិគមនិយមយកមកបង្រៀនយើងគឺអរិយធម៌អាណានិគមនិយមមិនមែនអរិយធម៌ប្រជាជនបារាំងទេ។

២.ក្តាប់បណ្ឌិតអក្សរសាស្ត្រខ្មែរដើម្បីលាក់អំពើលាមករបស់វាដោយខំបង្កើតពុទ្ធសាសនបណ្ឌិត្យហើយប្រមូលអ្នកប្រាជ្ញឱ្យមកធ្វើការបម្រើវា។ ដោយវិធីនេះ អាណានិគមនិយមបារាំងបានចូលទៅក្តាប់លោកសង្ឃឱ្យដើរស្របតាមនយោបាយវា។ ការចាត់តាំងរើសមេគណៈ មានរាជាគណៈជាដើម សុទ្ធតែត្រូវពិគ្រោះទទួលយល់ព្រមពី« លោកធំ »ទាំងអស់។

វប្បធម៌អាណានិគមនិយម ជាវប្បធម៌អាវាសែ វាបានពង្វក់មហាជន ជាពិសេសយុវកសិករឱ្យភ្លេចការងារ និងការតស៊ូប្រឆាំងនឹងពួកវា បែរជាយកកាមគុណស្រីញីជាធំ។ ឧទាហរណ៍ៈ

«សក្រវាទ៍អូនអើយ ផ្កាអំពិលទឹក
បងភ្ញាក់ពីព្រឹក អូនណាំទៅភ្ជួរស្រែ
បានមួយគន្លង ពីរគន្លងក៏យកដែរ
ដោះគោលែងខ្សែ អូនណាំដើរចង់ស្រី។»

មកដល់សម័យឯករាជ្យ សង្គមខ្មែរយើងឋិតនៅជាសង្គមពាក់កណ្តាលអាណានិគម និងពាក់កណ្តាលសក្តិភូមិ។ អក្សរសិល្ប៍ទាំងនោះខិតខំត្រាប់តាមអក្សរសិល្ប៍បរទេសជាច្រើន។ អក្សរសិល្ប៍ទាំងនោះ ពុំសូវមានប្រយោជន៍ប៉ុន្មានឡើយ ដូចមានអ្នកសិក្សាខ្លះបានសរសេរថា អក្សរសិល្ប៍ទាំងនោះច្រើនតែសម្រង់គំនិតពីរឿងប្រលោមបស្ចឹមប្រទេស និងជាស្នាដៃអ្នកនិពន្ធក្មេងៗ ដែលទទួលឥទ្ធិពលពីវប្បធម៌បរទេស។ ហេតុដូចនេះ ទើបកវី រ៉ឺណេ ដឺ ប៉េស (René de Pest) សរសេរចំអកឱ្យពួកអ្នកនិពន្ធក្មេងៗទាំងនោះថាៈ

« អ្នកស្រីពុំនៅតែម្នាក់ឯងទេ នាងមានស្វាមីម្នាក់ ប្តីម្នាក់ដែលចេះទាំងអស់
ប៉ុន្តែបើនិយាយតាមត្រង់គឺប្តីដែលអត់ចេះអ្វីសោះ
ពីព្រោះវប្បធម៌របស់គេបានមកដោយមានការលះបង់
ការលះបង់សាច់របស់ឯងនិងឈាមរបស់ឯង ការលះបង់ខ្លួនឯងដើម្បីអ្នកដទៃ
ការលះបង់ដើម្បីបរទេសនិយម និងអ្វីដែលគេញាត់ក្នុងខួរក្បាលរបស់យើង...»។

បែរមកមើលសិល្បៈទី៧ដែលជាមែកធាងមួយនៃវប្បធម៌ដែរនោះយើងឃើញថាលក្ខណៈគុណភាពនៃសិល្បៈនេះក៏ពុំខុសពីអក្សរសិល្ប៍ប៉ុន្មានដែរ។ ទស្សនិកជនចំពោះកុនមានច្រើនបែប។ បែបទីមួយគឺ ពួកវរជន

ដែលចូលចិត្តប្រជាប្រិយ។ គេរកកុនបរទេសដែលមានគុណភាពល្អ។ ទស្សនិកជនបែបទីពីរជាអ្នកមើលកុនមធ្យម។ ពួកនេះចូលចិត្តកុនបរទេសដែរឱ្យតែកុននោះមានដំណើររឿងហ៊ឹកហ៊ាក់ : កុនស៊ើបអង្កេត កុនអាចោរអាគិញ កុនផ្សងព្រេង។ កុនដូចជារឿង«សង្គ្រាមនិងសន្តិភាព»របស់លោក តុលស្តូយ ពុំមានសំណាងត្រូវគេសរសើរឡើយ ព្រោះរឿងនោះមានកម្រិតខ្ពស់ពេក។ ទស្សនិកជនបែបទីបីគឺអ្នកលក់បន្លែ អ្នកធាក់ស៊ីក្លូ កម្មករជាដើម។ ពួកខាងក្រោយនេះចូលចិត្តរឿងកំសត់ស្រក់ទឹកភ្នែក ជាមួយនិងការកំប្លែងរបស់ថ្លុកប្រជាប្រិយ។ គេទាំងអស់ខាងក្រោយនេះចូលចិត្តកុនខ្មែរ គឺដោយសារអ្នកទាំងនេះហើយ ដែលអ្នកកសាងភាពយន្តខ្មែរខិតខំតម្រូវចិត្ត។ កុនខ្មែរបើសង្ខេបមកមានពីរធុន។ កុនបែនមនោសញ្ចេតនាមួយធុន និងកុនរឿងព្រេង ហោះហើរមួយធុនទៀត។ កុនទាំងពីរបែបនេះមានគុណភាពនៅអន់ពេកណាស់។ អ្នកកសាងភាពយន្តទាំងនោះពុំអាចបង្កើតខ្សែភាពយន្ត ឱ្យល្អដូចបរទេសឡើយ ដោយមកពីពុំមានទុនច្រើនលើសលប់ដូចគេ។ ថាសាច់រឿងចុះពុំកើត ចំណែកឯអត្ថរូបវិញរឹតតែគួរឱ្យអាណោចអាធម្មណាស់ទៅទៀត។គេពុំមានខិតខំរិះរកស្រាវជ្រាវអំពីសម្លៀកបំពាក់នៃសម័យនីមួយៗទេ។ ដូចជាតួអង្គមហាសេដ្ឋី ទោះសម័យអង្គរក្តី សម័យសតវត្សទី១៩ក្តីស្លៀកពាក់តែរបៀបដដែលៗ។គឺមនុស្សម្នាក់មុខមាត់កាចសាហាវពាក់អាវកុតកត្រង់ពាក់មួកហាមធំរបស់ពួកអាណានិគមនិយម ហើយជក់ខ្សៀមួយផង។

រួមសេចក្តីមក យើងឃើញថា នៅក្នុងប្រទេសទន់ខ្សោយ ដូចប្រទេសខ្មែរយើងនេះវប្បធម៌ក៏ទន់ខ្សោយដែរ។ មិនតែប៉ុណ្ណោះពួកអ្នករកស៊ីនិងអ្នកកាន់អំណាចរួមដៃគ្នាបង្កើតវប្បធម៌ប្រវញ្ចលើភាពល្ងង់របស់អ្នកអាននិងទស្សនិកជន។ បានសេចក្តីថា សព្វថ្ងៃនេះ មហាជន ប្រជាជន នៅក្នុងដង្កៀបរបស់ពួកអ្នកកាន់អំណាចនិងពួកអ្នករកស៊ី។ដូចគ្នានេះដែរប្រសិនបើគេពិនិត្យទំនាក់ទំនងរវាងប្រទេសមួយទៅនឹងប្រទេសមួយគេឃើញថាការផ្សាយវប្បធម៌នៃប្រទេសទន់ខ្សោយបិតនៅក្នុងឃ្នាបរបស់ពួកមហាអំណាចចក្រពត្តិច្បាស់លាស់ណាស់។

តាមស្ថិតិគេដឹងថា ប្រទេសឧស្សាហកម្មលូតលាស់ទាំង៣២ នៅអឺរ៉ុបខាងលិច ព្រមជាមួយ«សហរដ្ឋអាមេរិក កាណាដា អូស្ត្រាលី នូវ៉ែលស៊េឡង់ ជប៉ុន» ដែលមានប្រជាជនមួយភាគបីនៃប្រជាជននៃពិភពលោកប៉ុណ្ណោះ ជាផលិតករសៀវភៅចេញផ្សាយចំនួន៨០% ក្នុងមួយឆ្នាំៗ លើពិភពលោកយើងនេះ មានប្រហែល ៤០០,០០០ចំណងជើងនិងសៀវភៅច្រើនជាង៧,០០០លានក្បាល។ចំណែកប្រទេសក្រៅពីនោះផលិតបាន ៩០,០០០ ចំណងជើង ហើយផ្សាយសៀវភៅបានតិចជាង ៧០០លានក្បាល។ គួរតែបញ្ជាក់ដែរថា ប្រទេសទាំងនោះ តំណាង៧០% នៃប្រជាជនក្នុងពិភពលោក។គេបានគន់គូរនៅឆ្នាំ១៩៦៥ ថានៅក្នុងចំណោមសៀវភៅបួនដែលលក់ ក្នុងប្រទេសអាហ្វ្រិក មានតែមួយទេដែលផលិតនៅក្នុងស្រុក បីទៀតសុទ្ធតែនាំមកពីបរទេសទាំងអស់ ហើយបើគិតជាទឹកប្រាក់វាត្រូវជា ៦៤លានដុល្លា។ បំណកប្រែក៏ជាទិដ្ឋភាពមួយបង្ហាញការវាតទី លុកលុយ នៃវប្បធម៌ប្រទេសឧស្សាហកម្ម លើប្រទេសទន់ខ្សោយដែរ។ ៧២%នៃសៀវភៅបកប្រែច្រើនមកពីអង់គ្លេស បារាំង រុស្ស៊ី និងអាល្លឺម៉ង់។ ហើយមានតែ៣%ទេ ដែលប្រែចេញពីភាសានៃប្រទេសទន់ខ្សោយ។

ឯមធ្យោបាយនៃការផ្សាយទៀតសោត ក៏នៅក្នុងកណ្តាប់ដៃនៃពួកមហាអំណាចទាំងអស់។ ប្រទេសសហរដ្ឋអាមេរិក កាណាដា ស៊ុយអែត ហ្វាំងឡង់ ជប៉ុន ដែលជាប្រទេសផលិតក្រដាសសម្រាប់ផ្សាយសុទ្ធសឹងតែជាប្រទេសអ្នកមានទាំងអស់។ នៅឆ្នាំ១៩៦៩ នៅស.រ.អា. ការប្រើប្រាស់ក្រដាសបោះពុម្ពនិងសរសេរ មានចំនួន៤៧.៣គ.ក្រ.ក្នុងប្រជាជនមួយនាក់។ ខាងអឺរ៉ុប១៩.៣ គ.ក្រ.ក្នុងប្រជាជនមួយនាក់។ ខាងអាហ្វ្រិក០.៩គ.ក្រ. ក្នុងប្រជាជនមួយនាក់។ខាងអាស៊ីភាគខាងត្បូង ០.៦គ.ក្រ. ប្រជាជនមួយនាក់។ ខាងអាហ្វ្រិក០.៩គ.ក្រ.ក្នុងប្រជាជនមួយនាក់។ខាងអាស៊ីភាគខាងត្បូង០.៦គ.ក្រ.ក្នុងប្រជាជនមួយនាក់ ( A lire le Monde diplomatique. Robert Escapit : Le Tiers-Monde reste sous la dépendance culturelle des grandes puissances, Janvier 1972 )។

បញ្ហាវប្បធម៌ខ្មែរ ពុំអាចដោះស្រាយតែក្នុងរង្វង់វប្បធម៌ប៉ុណ្ណោះ បានរួចជ្រះស្រឡះទេ។ ប៉ុន្តែវាជាប់ពាក់ព័ន្ធជាមួយនឹងបញ្ហានយោបាយ សង្គមកិច្ចសេដ្ឋកិច្ច យ៉ាងចាក់ស្រេះវិតរួត។ គេពុំអាចដោះស្រាយបញ្ហាមួយ ដោយពុំដោះស្រាយបញ្ហាមួយទៀតបានឡើយ។ ដូចនេះតើការស្វែងរកវប្បធម៌ជាតិមួយ ប្រកបដោយលក្ខណៈឯករាជ្យត្រូវធ្វើតាមមធ្យោបាយណា? ការនេះត្រូវធ្វើតាមលក្ខណៈតស៊ូជាចាំបាច់។ដោយសារវប្បធម៌ខ្មែរបិតនៅក្នុងឃ្នាបប្រវញ្ច របស់ វណ្ណៈជិះជាន់និងបរទេស ដែលប្រើគ្រប់មធ្យោបាយដើម្បីសង្កត់សង្កិន កុំឱ្យជាតិខ្មែរយើងរួចចេញពីនឹមអាណានិគមចាស់និងថ្មីបាន។ វប្បធម៌នៅជាមួយសង្គម។ ចង់ដូរវប្បធម៌ កសាងវប្បធម៌ថ្មី ដោយពុំដូរសង្គមជាការមួយសម្រេចទៅពុំបានឡើយ។

**វប្បធម៌សម្រាប់ជាតិ**

មុននឹងឱ្យយោបល់របស់យើងចំពោះការស្ថាបនាវប្បធម៌សម្រាប់ជាតិខ្មែរយើងយើងត្រូវដឹងចាំបាច់នូវលក្ខណៈសង្គម ដែលជាថ្នាលបណ្តុះវប្បធម៌នោះសិន លោកសង្គមវិទូ រ៉ូស៊េ បាស្ទីត (Roger Bastide) មានយោបល់ថា សង្គមនៃប្រទេសក្នុងអាស៊ីភាគអគ្នេយ៍យើងនេះ ជាសង្គមដែលមានលក្ខណៈ ទ្វេភាគ (Société dualiste)។ សង្គមនៃប្រទេសទាំងនោះ ទទួលការសង្កត់ សង្កិនពីកម្លាំងខាងក្រៅ ទាំងផ្នែកនយោបាយ ទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកវប្បធម៌។ គឺជាសង្គមដែលគេធ្វើឱ្យទក់ទី ស្ទិតស្រពោន។ គឺជាសង្គមដែលវប្បធម៌បែបប្រពៃណី មានលក្ខណៈចាស់ហួសសម័យ ពុំស៊ីគ្នានឹងការវិវត្តនៃតិចនិកសេដ្ឋកិច្ច ព្រមទាំងតម្រូវការរបស់ប្រជាជននាសម័យកាលឥលូវនេះផង។ ការជិះជាន់របស់ពួកអាណានិគមនិយម បានទុកស្នាមយ៉ាងជ្រាលជ្រៅ ក្នុងគំនិតស្មារតីនៃប្រជាជនប្រទេសទាំងនោះ។ ខ្លាំងជាងនេះទៅទៀត នៅពេលពួកអាណានិគមចាស់ចេញទៅ ពួកអាណានិគមថ្មីដែលប្រកបដោយចង្កូមមុតជាងពួកចាស់ទៅទៀត ចូលមកសង្កត់សង្កិនតាមគ្រប់មធ្យោបាយ។ប្រទេសទាំងអស់នោះបានឯករាជ្យត្រឹមតែសំបកក្រៅត្រឹមតែឃឺហោ។ឯករាជ្យសំខាន់គឺឯករាជ្យផ្នែកសង្គមកិច្ច។

បញ្ហាដែលកើតមាននៅក្នុងសសង្គមទាំងនោះ គឺទំនាស់គ្រប់ទិដ្ឋភាពនិងនៅក្នុងគ្រប់វិស័យ។ លោកជាតិពន្ធវិទូហ្សង់គ្វីស៊ីនីញេ (JeanCuisinier) បានចាត់ទុកថាសង្គមនៃប្រទេសទាំងនោះនៅក្នុងស្ថានភាពមួយដែលមានកម្លាំងពីរបុកគ្នា ប៉ះទង្គិចគ្នាជានិច្ច។ ទំនាស់រវាងអំណាចនយោបាយនិងអំណាចសេដ្ឋកិច្ច។ ទំនាក់ទំនងច្របូកច្របល់នៃប្រជាជាតិភាគតិចដែលក្តាប់អំណាចសេដ្ឋកិច្ចទាំងមូលនឹងប្រជាជាតិភាគច្រើនជាម្ចាស់ស្រុកដែលបាត់បង់អំណាចសេដ្ឋកិច្ច ទាំងអំណាចនយោបាយ។ ទំនាស់រវាងពួកប្រជាជនដែលរស់នៅក្នុងទុក្ខវេទនា គោកយ៉ាក នឹងវរជនមួយក្តាប់តូច ដែលរស់នៅក្នុងភាពសប្បាយចាក់ច្រាសរបៀបក្រអឺតក្រទមជិះជាន់សង្កត់សង្កិនឃុបឃិតជាមួយឈ្មួញបរទេស។ទំនាស់រវាងវប្បធម៌អឺរ៉ុបនឹងវប្បធម៌ជាតិ។ទំនាស់រវាងពួកស្នេហាជាតិពិតប្រាកដ នឹងពួកដែលគេហៅថា«ជាតិនិយម» ស្អីគេនោះ។ ទោះបីត្រូវជរាពិការ ទុរន់ទុរា ដោយចំហាយដ៏អាក្រក់របស់ពួកអាណានិគមនិយមចាស់និងការឈ្លានពាននៃពួកអាណានិគមនិយមថ្មីក៏ដោយអាវុធដ៏មុតថ្លាមួយដែលអាចឲ្យប្រទេសទន់ខ្សោយ ឈ្នះឧបសគ្គធំៗបាន គឺការភ្ញាក់រឭកចំពោះវប្បធម៌ជាតិដើម្បីប្រជាជន ដើម្បីវណ្ណៈ ដើម្បីរំដោះប្រជាជនចេញពីកម្រែលសក្តិភូមិ នាយទុន មូលធននិយម ចក្រពត្តិនិយម។ នៅក្នុងក្របខណ្ឌប្រយុទ្ធរំដោះជាតិនិងប្រជាជនការឲ្យតម្លៃទៅលើវប្បធម៌ជាតិបានផ្តល់ឲ្យប្រទេសទន់ខ្សោយនូវការភ្ញាក់រឭកមួយដ៏អស្ចារ្យប្រឆាំងនឹងវប្បធម៌សាបព្រោះដោយចក្រពត្តិ៖ កុនរបស់ពួកវាឃើញតែការកាប់សម្លាប់ ប្លន់ ភាពឃោរឃៅ ការសង្កត់សង្កិននៃពពួកអ្នកខ្លាំង(គ្រប់ផ្នែក៖ ផ្នែកអាវុធ លុយកាក់ អំពើថោកទាប ...) ការភ្លើតភ្លើន ការរវើរវាយ ការសប្បាយភ្លេចខ្លួនដូចសត្វមមាច អំពើពាលាអាវ៉ាសែគ្រប់បែប។

ការបំផុសវប្បធម៌ជាតិ ជាកត្តាមួយធ្វើឱ្យការរំដោះជាតិកាន់តែមាន លក្ខណៈស្រួចស្រាល់ កាន់តែឆាប់រហ័សជាស្ថាពរ និងជាមធ្យោបាយសម្រាប់ការពារប្រឆាំងតបនឹងចក្រពត្តិ ដែលខិតខំបញ្ចូលទស្សនៈ ភាសា

របៀបគិតរបស់វា អប់រំឲ្យមើលងាយមើលថោកវប្បធម៌ជាតិ។ យើងជឿច្បាស់ថា ប្រទេសខ្មែរយើងជាកំណាប់វប្បធម៌រាប់ពាន់ឆ្នាំមកហើយ ច្បាស់ជាមានជ័យជំនះលើ វប្បធម៌ពួកឈ្លានពាន(Guy de Boschère : Clefs pour le Tiers-Monde. Ed. Seghers 1973)

ក្នុងងការតស៊ូរំដោះខ្លួនចេញពីមរតកអាណានិគមនិងការឈ្លានពានរបស់ពួកចក្រពត្តិការពង្រឹងបុគ្គលិកលក្ខណៈជាតិ ជាអាយុជីវិតរបស់បដិវត្តន៍ពិតប្រាកដណាស់។ លក្ខណៈម្យ៉ាងទៀត គឺការលុបបំបាត់គម្លាតគ្នារវាង «បញ្ញវន្ត»និង«មហាជន»។ គឺជាការចាំបាច់ ក្នុងក្របខណ្ឌបំផុសបុគ្គលិក លក្ខណៈជាតិដែរ ដោយហេតុបញ្ញាជនជាច្រើននៅចូលចិត្តភាសាបរទេស ក្នុងការតស៊ូតទល់ជាមួយនឹងចក្រពត្តិនិយមនៅឡើយ។ យើងនិយាយនេះពុំមែនមានន័យថាយើងត្រូវតែទាត់ចោលភាសាបរទេសទាំងស្រុងឡើយ។តែជាមួយមហាជនយើងត្រូវប្រើភាសាជាតិ ទើបអាចបំផុសការភ្ញាក់រឭករបស់មហាជនបាន។ លោកសង្គមវិទូ រ៉ូស៊េ បាស្ទីត បានធ្វើកំណត់សម្គាល់ថា៖ «នៅពេលដែលគេប្រើបញ្ញត្តិអឺរ៉ុប គេធ្លាក់ខ្លួនចូលទៅក្នុងរបៀបគិតពិចារណា ផ្នែកបស្ចឹមប្រទេសស្រេចទៅហើយ»។កត្តាមួយទៀតដែលជួយជំរុញប្រទេសទន់ខ្សោយឲ្យចេញផុតពីភាពរណបគេផ្នែកវប្បធម៌ គឺសាមគ្គីភាពរវាងប្រទេសទន់ខ្សោយដូចគ្នា។ ដូចនេះហើយ ទើបយើងឃើញមានការរីកដុះដាលនៃមូលដ្ឋានជាច្រើន សមាជជាច្រើន អំពីវប្បធម៌ជាតិនេះ ដែលមានការជាប់ជិតស្និទ្ធនឹងទិសដៅនយោបាយផងដែរ : សមាជនៅ ដាកា នៅឡាហាវ៉ាន នៅអាល់ហ្សេ។ ការប្តូរបទពិសោធន៍រវាងជាតិមួយនឹងជាតិមួយទៀត ក៏ជាការសំខាន់ណាស់ដែរ។ ភស្តុតាងនេះកាន់តែបញ្ជាក់យ៉ាងច្បាស់បេះពុំដាច់រវាងនយោបាយ និងវប្បធម៌។ វប្បធម៌សិតឡើងដោយអ្នកបដិវត្តជាមរតកមួយថ្មីស្រឡាងចំពោះវប្បធម៌ពិភពលោក។ យើងសង្កេតឃើញថាអ្នកតស៊ូនយោបាយជាច្រើនសុទ្ធសឹងជាអ្នក វប្បធម៌មួយរូបដែរ។

ក្រោយដែលបានពិនិត្យមើលអក្សរសាស្ត្រខ្មែរតាំងពីសម័យដើមរហូតមកដល់សព្វថ្ងៃនេះយើងសួរថា តើអក្សរសាស្ត្រខ្មែរយើងត្រូវមានលក្ខណៈដូចម្តេច ក្នុងក្របខណ្ឌប្រទេសទន់ខ្សោយដែលយើងរៀបរាប់ដូចខាងលើនេះ? ដំបូងយើងត្រូវបដិសេធគំនិតយល់ខុសកសាងសិល្បៈដើម្បីសិល្បៈឬកំណាព្យដើម្បីកំណាព្យឱ្យជ្រះស្រឡះ ព្រោះដូចយើងបានវែកញែកមើលអក្សរសិល្ប៍ខ្មែរ រួចមកហើយសិល្បៈឬកំណាព្យ សុទ្ធតែកើតឡើងពីមនុស្សហើយធ្វើសម្រាប់ក្រុមណាមួយជាដាច់ខាត។ ច្បាប់ក្រម ច្បាប់ស្រី កើតឡើងសម្រាប់សង្គមសក្តិភូមិ។គតិលោកកើតឡើងក្នុងសម័យអាណានិគមនិយមហើយស្របតាមរបបនោះឯង។អ្នកប្រាជ្ញដ៏ចំណានម្នាក់ពោលថា៖ «អ្នកនិពន្ធមិនត្រូវគ្រាន់តែចម្លងហេតុការណ៍ ដែលមាននៅក្នុងសង្គមប៉ុណ្ណោះទេ ប៉ុន្តែត្រូវរកមធ្យោបាយដឹកនាំសង្គមឲ្យបានដើរទៅរកផ្លូវចម្រើន យុត្តិធម៌ និងសមភាព»។

ដូចសេចក្តីខាងលើនេះ អ្នកនិពន្ធត្រូវដើរមុខប្រជាជន បង្ហាញវែកផ្លូវជឿនលឿនចំពោះប្រជាជន។ អ្នកនិពន្ធត្រូវលើកត្រដាងគុណសម្បត្តិប្រសើរនៃប្រជាជនទៅអនាគតមិនត្រូវមាននាទីចម្លងផ្ចិតត្រដាងសកម្មភាពពុករលួយ ទ្រុឌទ្រោមឲ្យគេដើរតាមនោះទេ។ ដើម្បីឲ្យស្គាល់ការតស៊ូយុត្តិធម៌របស់ប្រជាជន អ្នកនិពន្ធត្រូវដាក់ខ្លួនជាប្រជាជន មិនត្រូវគ្រាន់តែចំអើតឈ្ងោកមើលពីលើប៉ុណ្ណោះទេ។ អ្នកនិពន្ធត្រូវសរសេររឿងមានលក្ខណៈប្រជាជាតិ ប្រជាជន និង ស្សង់។

ប្រជាជាតិបានសេចក្តីថា យើងត្រូវលើកប្រជាជនជាធំ។អ្នកតំរូតួឯករបស់យើងទាំងប៉ុន្មានគឺ ប្រជាជនកម្មករ កសិករ អ្នកបង្កើតផលិតផល។ មួយចំណែកទៀតប្រយោគ ឃ្លា របៀបសរសេរ យើងត្រូវសរសេរឱ្យប្រជាជនងាយយល់។ យើងត្រូវបញ្ចាំងក្នុងរឿងនូវការតស៊ូរបស់ប្រជាជនទល់នឹងធម្មជាតិ ការតស៊ូស្វិតស្វាញរបស់ប្រជាជន ដើម្បីសិទ្ធិសេរីភាព សន្តិភាព ប្រជាធិបតេយ្យ និងឯករាជ្យភាព។

ស្សង់បានន័យថា វប្បធម៌យើងត្រូវតែផ្អែកទៅលើការជាក់ស្តែង យើងជម្រុះចោលជំនឿគ្មានសមហេតុសមផល។មានតែយើងត្រូវផ្អែកទៅលើស្សង់ទេដែលអាចសម្រួលកម្លាំងប្រជាជនយើងក្នុងការបង្កបង្កើនផល។

បន្ថែមលើនេះទៅទៀតបើគេពោលពីវប្បធម៌គេពុំត្រូវនឹកឃើញតែអក្សរសរសេរលើក្រដាសតែប៉ុណ្ណោះទេ។ ពិតមែនហើយថាសៀវភៅសរសេរអំពីវប្បធម៌បដិវត្តន៍ ជាអាវុធមួយសំខាន់ណាស់។ លោក ប៊ែតុល ប្រិច បានពោលថាៈ«អ្នកអត់ឃ្លានទាំងឡាយ ចូរអ្នកលើកសៀវភៅឡើង ដោយសៀវភៅគឺជាអាវុធមួយ» ( Affamé saisis toi du livre . Le livre est une arme - B. Brecht )។ ទោះជាយ៉ាងណាក៏ដោយ សៀវភៅតែមួយពុំគ្រាន់ទេ ត្រូវតែអ្នកបង្កើតសៀវភៅនេះចូលរួមរលាយសាច់មួយ ជាមួយប្រជាជនក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅតែម្តង។ ការប្តូរចរិតអាកប្បកិរិយាប្រជាជនទាំងអស់ឲ្យភ្ញាក់រឭក ជាទិសដៅចម្បងនៃវប្បធម៌ជឿនលឿន។

មានពួកអ្នក«អន្ទើស»«មហាបញ្ញវន្ត»ខ្លះក្រោយពីអាណានិគមចេញបាត់ទៅពួកអស់លោកពុំបានគិតគូរជួយអូសទាញ ចេញពីសំណល់ទម្ងន់សង្កត់សង្កិនគ្រប់ផ្នែក ទាំងសេដ្ឋកិច្ច ទាំងសង្គមកិច្ច ទាំងនយោបាយ និងទាំងផ្នែកវប្បធម៌ទេ បែរជាតាំងខ្លួនជាបន្លាស់ពួកអាណានិគមនិយមទាំងនោះទៅវិញ។ពួកទាំងនោះក៏តាំងធ្វើគ្រាប់ចៅហ្វាយចាស់ ព្រោះពួកអស់លោកនោះធ្លាប់លិទ្ធកាកអំណាច លាភសក្ការៈ ខ្លះទៅហើយ នៅសម័យជិះជាន់នោះ។ ភ្លក់ទៅឃើញថាឆ្ងាញ់ញ៉ាមមាត់ ពួកអស់នោះក៏តាំងរកមធ្យោបាយគ្រប់បែបយ៉ាង ពង្រឹងអំណាចប្រមូលលាភសក្ការៈរបស់ខ្លួនតទៅទៀត។អស់លោកដឹងច្បាស់ថាពុំអាចកាន់អំណាចបានយូរ ដោយគ្មានការគាំទ្រពីប្រជាជនបាននោះទេ។ពួកអស់នោះក៏តាំងបញ្ចេញកម្មវិធីកសាងស្រុកជួយប្រជាជនដោយមានផែនការយ៉ាងមហាជាក់ច្បាស់ក្នុងគ្រប់វិស័យ។ប៉ុន្តែដោយពួកនោះតាំងចិត្តចេញពីពោះរៀនពោះតាំងជាស្រេចទៅហើយថា នឹងពង្រឹងអំណាចជិះជាន់ប្រជាជន បានសេចក្តីថា ដោយពួកនោះ មាក់ងាយមាក់ថោកប្រជាជនស្រេចរួចទៅហើយ ដោយធាតុពួកនោះជាធាតុប្រវញ្ច ដោយពួកនោះគ្មានធាតុប្រជាជនបន្តិចបន្តួចសោះនោះអស់លោកក៏បានបង្កើតកម្មវិធីមួយគ្មានជាប់ទាក់ទងទៅនឹងប្រយោជន៍ប្រជាជនទាល់តែសោះ។ ដោយមកពីកម្មវិធីទាំងនោះពុំមានជាប់នឹងតម្រូវការរបស់ប្រជាជន ប្រជាជនក៏ពុំទទួលកម្មវិធីនោះ អ្នកអន្ទើសថាប្រជាជនពុំយល់មហាកម្មវិធីរបស់អស់លោក ប្រជាជនជាហ្វូងមនុស្សមហាល្ងង់ដូចក្របី ជាហ្វូងចៀម ជាបាតមនុស្សអត់ចេះគិតពិចារណារបៀបប្រវញ្ចដូចពួកអស់នោះអត់ចេះកាច់រាងវាយឫកបរទេសដូចអស់លោកពុំចេះអក្សរសិល្ប៍ដ៏ខ្ពង់ខ្ពស់របស់ចៅហ្វាយចាស់និងថ្មីដូចអស់លោក អត់ដឹងការលូតលាស់នៃស្បង់ដូចអស់លោក។ ពួកអស់លោកក៏មើលងាយប្រជាជន ហើយចាត់ទុកថាមានតែអស់លោកទេ ដែលជាមនុស្សខ្ពង់ខ្ពស់ ត្រូវតែស្តាប់បង្គាប់អស់លោក។

ការជិះជាន់របស់ពួកអ្នកអន្ទើសទាំងនេះ ត្រូវប្រជាជនភ្ញាក់រឭកបកអាក្រាត មុខខ្មៅក្រខ្វក់របស់ពួកនោះជាញឹកញយ។ ដោយឃើញដូច្នោះ ពួកមហាបញ្ញវន្ត ក៏តាំងភិតភ័យដេកគិតរកមធ្យោបាយពង្វក់មហាជនបង្អាប់ស្មារតីកុំឲ្យភ្ញាក់រឭកបាន។ពួកនោះក៏តាំងជះលុយជះកាក់បាចសាចវប្បធម៌ពុករលួយស្អុយក្រខ្វក់មកលើមហាជន។មហាជនខ្លះដែលគ្មានស្មារតីពុំបានរឹងប៉ឹង ក៏ភ្លើតភ្លើននឹងវប្បធម៌របស់ពួកអស់នោះទៅ។ ឃើញដូចនោះពួកជិះជាន់ទាំងនោះក៏ស្រែកថា ឃើញទេប្រជាជនអត់ចេះគិតអ្វីទេ ចេះត្រឹមតែ ស៊ីយនិង ម៉ង់ដូលីនតែប៉ុណ្ណោះ គ្មានយល់នយោបាយ យល់ប្រជាធិបតេយ្យអីដូចពួកខ្លួនទេ។នៅពេលដែលពួកអាណានិគមវាមកបើកគូបវារកស៊ីទាំងកំហាល់ នៅក្នុងស្រុកខ្មែរយើង ពួកវណ្ណៈជិះជាន់ក្នុងស្រុកបានជញ្ជក់យករសជាតិវប្បធម៌អរិយធម៌បរទេសទាំងនោះឥតសំចៃដៃ។ពួកវារៀនភាសាជិះជាន់ទាំង ងងើលឥតអៀនខ្មាស់ ខំលេបវប្បធម៌ពួកទាំងនោះ ទាំងវិធី ទាំងរបៀបរស់នៅទាំងរបៀបគិត។

ជំនាន់នីមួយៗត្រូវតែស្គាល់ឱ្យច្បាស់នូវបេសកកម្មរបស់ខ្លួន ឬមួយយើងបំពេញបេសកកម្មរបស់យើង

ឬក្បត់ភារកិច្ចរបស់យើងតែប៉ុណ្ណោះ។ នៅប្រទេសខ្មែរយើងនេះរៀមច្បងយើង បានបំពេញមុខងាររបស់ខ្លួន ដោយបានប្រឆាំងប្តូរផ្តាច់ទល់នឹងការខិតខំពង្រិចពង្រិលវប្បធម៌ជាតិ ដោយពួកអាណានិគមហើយបានរៀបចំ និងបង្ហំការតស៊ូក្នុងបច្ចុប្បន្នកាលនេះ។ ភារកិច្ចយើងឥលូវនេះ នៅចំពោះមុខប្រវត្តិសាស្រ្ត ជាមួយនឹងការសម្រេចចិត្តរបស់យើងថានឹងវាយបំបាក់គ្រប់ការជិះជាន់ របស់ពួកអាណានិគមសម័យថ្មី គឺរៀបចំជានិច្ចនូវគោលការណ៍ទាមទារ ការតស៊ូវែកមុខពិតប្រាកដរបស់ចក្រពត្តិនិងបរិវាដាច់ថ្លៃរបស់វា។ ពួកវណ្ណៈជិះជាន់និងចក្រពត្តិខិតខំបន្ថយកំហឹងមហាជន ដោយពួកវាធ្វើហាក់ដូចជាដោះស្រាយបញ្ហា។ នៅពេលមហាជនតវ៉ាភ្លាម ពួកវាធ្វើហាក់ដូចជាយល់ច្បាស់ណាស់ នូងការទាមទាររបស់មហាជន ដោយធ្វើជាទទួលស្គាល់យ៉ាងសុភាពរាបសារស្ថានការណ៍ដ៏លំបាក ដែលយើងជាប់នៅក្នុងនោះ។ ប៉ុន្តែពួកវាពុំអាចដោះស្រាយបញ្ហាទាំងនោះបានឡើយ បើមិនកាត់ទោសពួកវាមុនគេទេនោះ មុនដំបូងពួកវាធ្វើជាផ្តល់ជំនួយប៉ុណ្ណោះ បង្កើតអង្គការឱ្យជួយសម្រាលនេះជួយសម្រាលនោះ។ពួកវណ្ណៈជិះជាន់និងខ្ញុំកញ្ជះដាច់ថ្លៃរបស់វាពុំអាចដោះស្រាយបញ្ហាទាំងនោះបានឡើយ។បើវាដោះស្រាយវិញគឺដោះស្រាយដោយបន្ថែមចំនួនប៉ូលីសបង្កើនចំនួនទាហាននិងបាញ់សម្លាប់អ្នកតស៊ូយ៉ាងឃោរឃៅ។

យើងជាយុវជនជំនាន់នេះដែលមានភារកិច្ចកសាងវប្បធម៌ជាតិមួយយើងកុំធ្វើដូចមហាបញ្ញវន្តខ្លះដែលឈ្លក់ងប់ងល់នឹងវប្បធម៌បរទេសនោះឱ្យសោះ។ យើងសង្កេតឃើញថា ជាយូរណាស់មកហើយ ពួកអ្នកស្រាវជ្រាវអឺរ៉ុបជាច្រើនបានបំផុសអរិយធម៌ចាស់ៗរបស់យើងប្រពៃណីទំនៀមទម្លាប់ចាស់ៗដែលកប់បាត់ក្នុងពេលវេលា និងក្នុងធម្មជាតិ។ ជាការល្អម្យ៉ាងដែរហើយ ដែលធ្វើខ្មែរយើងឱ្យស្គាល់ប្រពៃណីរបស់ខ្លួន។ប៉ុន្តែប្រពៃណីវាមានល្អ មានអាក្រក់។មានទំនៀមទម្លាប់ ជំនឿខ្លះពុំស៊ីនឹងតម្រូវការនៃសង្គម ដែលវិវត្តមកដល់សព្វថ្ងៃនេះទេ។ សូមកុំច្រឡំឱ្យសោះវប្បធម៌ប្រពៃណីនិងវប្បធម៌ជាតិ។ ពួកវណ្ណៈជិះជាន់សព្វថ្ងៃ និងពួកចក្រពត្តិ វាខំឃោសនាថា វាជាអ្នករក្សាប្រពៃណីខ្មែរ តែតាមការពិតគឺជាកលល្បិចរបស់វា ដែលផ្សព្វផ្សាយតែប្រពៃណីទំនៀមទម្លាប់ ដែលកើតឡើងក្នុងសម័យអាប់អោន ដូចជាសម័យក្រោយអង្គរជាដើម។ គេអាចកសាងវប្បធម៌ប្រពៃណីដាច់ដោយឡែកតែម្នាក់ឯងបាន ព្រោះប្រពៃណីវានៅក្រៅការវិវត្តរបស់សង្គម។ តែបើគេនិយាយពីស្ថាបនាវប្បធម៌ជាតិគេត្រូវភ្ជាប់បញ្ហាដទៃទៀតដែលនៅជាប់ជិតស្និទ្ធជាមួយការប្រែប្រួលនៃសង្គមគឺសេដ្ឋកិច្ចនិងនយោបាយ។ បើគេចង់បំផុសវប្បធម៌ជាតិ គេត្រូវតែបំផុសជាស្វ័យប្រវត្តិ នូវសេដ្ឋកិច្ចជាតិនិងនយោបាយជាតិ។ តែគេបំផុសឯកោនោះ គឺគេបំផុសវប្បធម៌ប្រពៃណីហើយ។ យើងយល់ថានៅក្នុងបញ្ហាជីវភាពប្រជាជនជាពិសេសនៅក្នុងក្របខណ្ឌអភិវឌ្ឍជាតិ តើការដឹងថាខ្លួនមានអរិយធម៌ខ្ពង់ខ្ពស់ថាខ្លួនចុះពីអំបូរខ្មែរមនវាមានផ្លាស់ប្តូរអ្វីខ្លះចំពោះជីវភាពប្រជាជន ? ប្រជាជននៅតែវេទនាខ្លោចផ្សារដដែលសេដ្ឋកិច្ចនៅតែជាសេដ្ឋកិច្ចខ្ញុំគេដដែល នយោបាយក៏នៅតែនយោបាយរណបគេដដែល។ នៅពេលដែលវណ្ណៈជិះជាន់ជាមួយចក្រពត្តិ វាឃោសនាថា វាជាអ្នករក្សាប្រពៃណីខ្មែរនោះ គឺវាចង់ឱ្យប្រជាជនខ្មែររក្សាទំនៀមទម្លាប់ឃើតយ៉ារមួយ ផ្ទុយប្រជាជនកុំឱ្យភ្ញាក់រឭក វាចង់ឲ្យតែប្រជាជនលិចលង់ ក្នុងជំនឿពុំសមហេតុសមផល ផ្ទុយនឹងរបកគំហើញនៃស្យង់។ ដូចនេះជាការបោកប្រាស់មួយ ជាល្បែងបន្លំភ្នែកមហាជនមួយ ជាអំពើក្បត់ប្រជាជនឥតប្រកែកបាន។

យុវជនយើងជំនាន់នេះ ជាមួយនឹងមហាបញ្ញវន្ត ត្រូវយល់ឱ្យច្បាស់ថា គេពុំអាចរកអ្វីជាជាតិបានដោយការគ្រាប់តាម ការពិចារណារបស់បរទេស ឬក៏វិលត្រឡប់ទៅរកប្រពៃណីអតីតកាលនោះបានឡើយ។ គេអាចជ្រួតជ្រាបន័យថាជាតិបានតែតាមរយៈការប្រយុទ្ធរបស់ប្រជាជនប្រឆាំងនឹងពួកចក្រពត្តិនិងបរិវារដាច់ថ្លៃរបស់វា។

គេសង្កេតឃើញថា នៅពេលដែលពួកមហាបញ្ញវន្តចង់បង្កើតជាស្នាដៃវប្បធម៌មួយ គេតែងតែខ្ចីតិចនិកនិងភាសាមួយពីពួកជិះជាន់។ គេគ្រាន់តែស្លៀកពាក់ខោអាវថ្មី ឱ្យតិចនិកទាំងនោះតែប៉ុណ្ណោះ។ ប៉ុន្តែគេនៅធំ

ក្លិនបរទេសនៅឡើយ។ បញ្ញវន្តដែលចង់រកលក្ខណៈជាតិនោះ មានឫកពារសុទ្ធសាធជា បរទេស។ នៅក្នុងករណីខ្លះ គេខិតខំប្រើគ្រាមភាសា ដើម្បីបង្ហាញឱ្យឃើញថាពួកគេបិតនៅជិតប្រជាជនបំផុត ប៉ុន្តែគំនិតរបស់គេ បញ្ហាចោទរបស់គេពុំស៊ីគ្នាបន្តិចបន្តួចសោះនឹងបញ្ហាប្រជាជន។ពួកគេខិតខំបំផុសអ្វីដែលហួសសម័យអ្វីដែលថយក្រោយ។ ករណីនេះ ពុំគ្រាន់តែប្រឆាំងនឹងដំណើរប្រវត្តិសាស្ត្រប៉ុណ្ណោះទេ តែប្រឆាំងនឹងប្រជាជនថែមទៀត។ នៅពេលដែលប្រជាជនតស៊ូអាវុធនិងតស៊ូនយោបាយប្រឆាំងនឹងចក្រពត្តិ ប្រពៃណីត្រូវតែដូរទៅតាមនោះដែរ។ ប្រជាជនដែលតស៊ូដោយអាវុធពុំអាចទទួលបានអ្វីដែលគេហៅថា ប្រជាភិចុតឡើយ ហើយបញ្ញវន្តដែលតោងកន្ទុយមហាជនប្រជាជន គ្រាន់តែជាអ្នកឱកាសនិយម ឬជាអ្នកឃឹតយ៉ារប៉ុណ្ណោះ។

នៅក្នុងផ្នែកសិល្បៈក៏ដូចគ្នាដែរ សិល្បករតែងតែខិតខំចម្លងគ្រាប់តាម សិល្បៈអង្គរ ហើយនៅងាប់តែនឹងសិល្បៈនេះ។ គេពុំខ្មាសដូនតាយើងដែល បន្សល់មរតកយ៉ាងថ្លៃថ្លាមកឱ្យយើង ឯចំណែកយើងវិញអត់បានបង្កើតអ្វីថ្មីសោះ។ គេចាត់ទុកថាសិល្បៈនេះជាសិល្បៈអមតៈ ជាគំរូសិល្បៈ ជាថេរៈរបស់ជាតិ។ សិល្បករទាំងនោះភ្លេចគិតថារូបភាពនៃគំនិតស្ថានការណ៍ពិភពលោកទំនាស់ក្នុងសង្គមបានកែប្រែគំនិតរបស់ប្រជាជនជ្រៅណាស់ទៅហើយ។ អ្វីដែលពួកនោះបាញ់ឆ្ពោះទៅរក បិតនៅត្រឹមតែជាក្អែលជាកាកនៃគំនិតសក្តិភូមិ ជាអសុភ ជាចំណេះស្ងួញឥតរស់រវើកសោះឡើយ។

បញ្ញវន្តនិងយុវជនត្រូវដឹងថា ប្រសិនបើខ្លួនចង់កសាងស្នាដៃជាតិមួយពិតប្រាកដ ត្រូវតែដឹងថាការពិតរបស់ប្រជាជាតិគឺជាការជាក់ស្តែងរបស់ប្រជាជាតិ។គេត្រូវតែចូលប្រឡូកជាមួយកន្លែងដែលពុះពារដែលនឹងចម្អិនឱ្យគេនូវចំណេះវិជ្ជាថ្មី គឺចំណេះវិជ្ជាសម្រាប់ប្រជាជន។ គឺមានតែលក្ខខណ្ឌនេះមួយគត់ ដែលអាចពង្រឹងស្មារតីជាតិក្នុងខួរក្បាលយុវជនខ្មែរយើងបាន។ នៅប្រទេសខ្មែរយើង យុវជនយើងតែងបានទទួលការសប្បាយ ដូចយុវជនប្រទេសមូលធនដែរ។ ដូចជារឿងប្រលោមស៊ើបអង្កេតវាយតប់សាហាវៗ ម៉ាស៊ីនបាញ់កូនឃ្លីលើតុ រូបអាសអាភាស អក្សរសិល្ប៍ផ្នែកកាមារម្មណ៍ កុនហាមចំពោះក្មេងអាយុតិចជាង១៦ឆ្នាំ...។ ការប៉ះទង្គិចរវាងអរិយធម៌មូលធនជាមួយអរិយធម៌ខ្មែរបាន ធ្វើឱ្យក្រឡាប់ផ្កាប់ផ្ងារទម្លាប់គំហើញរបស់យុវជនអស់នោះទាំងស្រុង។ ចិត្តថ្លើមរបស់យុវជន អារម្មណ៍របស់យុវជនពុំអាចទប់ទល់ នឹងគ្រឿងស្រើបស្រាលទាំងនោះបានឡើយ។ ផ្នែកកីឡាក៏យ៉ាងនោះដែរ គឺគេយកទស្សនៈមូលធនចំពោះកីឡាមកអនុវត្ត។ គេពុំបានឲ្យយុវជនកម្ពុជាមានស្មារតីភ្ញាក់រឭកទេ។ តែជា យុវជនមានសាច់ដុំល្អ។ កីឡាប្រសិនបើគេពុំបញ្ចូលទៅក្នុងការស្ថាបនាជាតិទេ ប្រសិនបើគេកសាងមនុស្សមានសាច់ដុំ មនុស្សចេះទាត់ធាក់ ប៉ុន្តែជាមនុស្សខ្វះស្មារតីជាតិហើយនោះ កីឡាមុខតែអស់ន័យចំពោះខ្លួនឯងតែម្តង។

រួមសេចក្តីមក យើងត្រូវបញ្ចូលគ្រប់សកម្មភាពសង្គម វប្បធម៌សង្គមទៅក្នុងក្របខណ្ឌកសាងជាតិស្ថាបនាជាតិនិងអភិវឌ្ឍជាតិជាដាច់ខាត។យើងត្រូវតែយល់ឲ្យច្បាស់ខ្លួនយើងម្នាក់ៗថាយើងពុំត្រូវលើកស្ទួយអ្វីដែលជាបុគ្គលនោះទេឬស្វែងរកអ្នកដឹកនាំម្នាក់ដ៏មហស្ចារ្យនោះឡើយ។ទទួលខុសត្រូវក្នុងប្រទេសទន់ខ្សោយត្រូវដឹងថាអ្វីៗទាំងអស់ផ្អែកទាំងស្រុងទៅលើការអប់រំមហាជនការតម្លើងស្មារតីភ្ញាក់រឭកគឺជាទង្វើនយោបាយនីយកម្ម។

គេតែងតែស្មានដោយឆ្គួតថាអបរំនយោបាយចំពោះប្រជាជនគឺត្រូវតែធ្វើឱ្យបានទៀងទាត់នូវសុន្ទរកថានយោបាយចំពោះមហាជន។ នៅពេលដែលអ្នកដឹកនាំថ្លែងសុន្ទរកថា ជារបៀប មហាបណ្ឌិត អំពីព្រឹត្តិការណ៍ជាតិបែបនេះហើយ គេហៅថាអប់រំមហាជន។ ដែលហៅថានយោបាយនីយកម្មនោះ គឺការលើកគំនិតធ្វើឱ្យភ្ញាក់រឭកបង្កើនគំនិតតស៊ូ។គឺជាការខិតខំពន្យល់ឱ្យមហាជនជ្រួតជ្រាបថាអ្វីៗទាំងអស់ផ្អែកទាំងស្រុងទៅលើមហាជននេះឯងអ្វីៗសម្រេចចេញទៅកើតក៏ដោយសារមហាជនទាំងអស់។គេអាចអប់រំមហាជនបានទាល់តែគេដាក់ខ្លួនជាសិស្សរបស់មហាជន។ប្រសិនបើគេតាំងខ្លួនជាអង្គម្ចាស់នៃមហាជនប្រសិនបើគេចាត់ទុកខ្លួនគេ

ជាអ្នកថ្នាក់លើ ប្រកបដោយទឹកមុខខ្ពង់ខ្ពស់ មើលមហាជនពុំពេញភ្នែក ក្នុងករណីនេះ ទោះបីខ្លួនយើងមានទេពកោសល្យយ៉ាងណាក៏ដោយ ទេពកោសល្យនោះនឹងក្លាយទៅជាឥតប្រយោជន៍ចំពោះមហាជន ហើយកិច្ចការរបស់យើងនឹងក្លាយទៅជាអសារឥតការ។ អ្នកនិពន្ធដែលសរសេរវប្បធម៌សម្រាប់ប្រជាជន ត្រូវតែសរសេរឡើងក្នុងគោលបំណងបង្ហាញអនាគត បបួលគេឱ្យចូលមកប្រឡូក និងចាក់គ្រឹះនៃសេចក្ដីសង្ឃឹមមួយ។ ប៉ុន្តែដើម្បីធានាអះអាងសេចក្ដីសង្ឃឹមនោះ ឱ្យមានពន្លឺ និងមានទម្ងន់ គេត្រូវតែចូលរួមក្នុងការប្រយុទ្ធរំលាយខ្លួនទាំងសាច់ទាំងឈាមក្នុងការរំដោះជាតិ។គេអាចនិយាយពីអ្វីៗទាំងអស់បានដោយពុំកម្រើកម្រាមដៃបាន តែបើគេនិយាយពីបដិវត្តន៍ គេត្រូវតែដំឡើងសាច់ដុំរបស់គេ ចូលរួមក្រោកឈរឡើង នឹងធ្វើឱ្យប្រជាជនក្រោកឈរឡើងដែរ។

ការទទួលខុសត្រូវនៃយុវជន ពុំមែនការទទួលខុសត្រូវចំពោះវប្បធម៌ជាតិ តែមួយមុខប៉ុណ្ណោះទេ តែជាការទទួលខុសត្រូវចំពោះជាតិទាំងមូលតែម្ដង។ វប្បធម៌ជាតិគ្រាន់តែជាទិដ្ឋភាពមួយរបស់ជាតិប៉ុណ្ណោះ។ បញ្ញវន្ត អ្នកនិពន្ធ យុវជន ពុំត្រូវជ្រើសរើសកម្រិតនៃការតស៊ូរបស់ខ្លួនទេ ឬវិស័យដែលខ្លួនត្រូវប្រយុទ្ធទេ។ ក្នុងការប្រយុទ្ធដើម្បីវប្បធម៌ជាតិ មុនដំបូងបង្អស់ត្រូវប្រយុទ្ធដើម្បីរំដោះជាតិដែលជាចង្ក្រានបញ្ចេញវប្បធម៌ជាតិ។ ពុំមានការប្រយុទ្ធដើម្បីវប្បធម៌ជាតិដាច់ចេញពីការរំដោះប្រជាជាតិទេ។វប្បធម៌ជាតិកកើតជារូបរាងនិងអត្ថន័យឡើង តាមរយៈការប្រយុទ្ធនេះឯង ក្នុងគុក នៅមុខភ្លើង នៅមុខបន្ទាយខ្មាំង។ យើងត្រូវធ្វើកិច្ចការតស៊ូឱ្យស៊ីសង្វាក់ជាមួយប្រជាជន ក្នុងទិសដៅបញ្ជាក់ឲ្យច្បាស់លើអនាគត រៀបចំទីលានដែលរីកស្គុះស្គាយឡើង នូវវប្បធម៌ជាតិមួយដ៏រឹងប៉ឹង។វប្បធម៌ជាតិពុំមែនជាប្រពៃណីទេវប្បធម៌ជាតិពុំមែនជាគំនរកម្ទេចគំនរនៃកាយវិការសុទ្ធសាធនោះឡើយ ដែលគ្មានជាប់បន្តិចបន្តួចសោះ ទៅនឹងជីវភាពរាល់ថ្ងៃនៃប្រជាជនទេ។ វប្បធម៌ជាតិគឺជាសំណុំកម្លាំងខិតខំទាំងអស់របស់ប្រជាជននៅក្នុងវិស័យគំនិតដើម្បីបរិយាយបង្ហាញហេតុផលនិងរៀបរាប់អំពីសកម្មភាពរបស់ប្រជាជនក្នុងការតស៊ូ ដែលប្រជាជនខ្លួនឯងបានកសាងឡើង និងសម្អិតសម្អាងឡើង។

វប្បធម៌របស់ប្រទេសខ្មែរយើង ត្រូវតែនៅជាស្នូលនៃការតស៊ូរំដោះជាតិ រំដោះប្រជាជន។ គឺការប្រយុទ្ធដើម្បីការរស់រាននៃជាតិនេះហើយដែលបណ្ដុះវប្បធម៌ជាតិបើកទ្វារសម្រាប់ការបង្កបង្កើតថ្មី។កម្ពស់នៃវប្បធម៌ជាតិលូតលាស់ទៅតាមកម្ពស់នៃការតស៊ូពិតប្រាកដណាស់។ ប្រសិនបើគេទុកដាក់វប្បធម៌ជាបាតុភាពនៃមនសិការជាតិយើងមិនញញើតនឹងនិយាយថាមនសិការជាតិជារូបភាពខ្ពស់បំផុតនៃវប្បធម៌ជាតិ។គឺតាមរយៈមនសិការជាតិនេះហើយ ដែលមនសិការអន្តរជាតិផុសឡើង គឺលើកមុខលើកមាត់យើងលើឆាកប្រវត្តិសាស្ត្រសកលលោក។ ហើយការផ្ទុះចេញព្រមគ្នានៃមនសិការទាំងពីរនេះហើយ ដែលជាថ្នាលបណ្ដុះវប្បធម៌ជាតិ។

ប្រសិនបើយើងរកដំណាក់ការនៃវិវត្តន៍វប្បធម៌របស់ប្រទេសយើង យើងឃើញមានដំណាក់ការពីរ។ នៅក្នុងដំណាក់ការទីមួយវប្បធម៌យើងទទួលឥទ្ធិពលមរតកពីប្រទេសអាណានិគមចាស់និងថ្មី។មិនតែប៉ុណ្ណោះវប្បធម៌យើងមានលក្ខណៈអតីតកាលនិយមច្រើន។ដំណាក់ការទីពីរគឺយុវជនយើងជំនាន់នេះត្រូវបង្កើតវប្បធម៌ប្រយុទ្ធមួយ វប្បធម៌បដិវត្តន៍មួយ វប្បធម៌ជាតិមួយ។ នៅក្នុងដំណាក់ការនេះបុរសស្ត្រីជាច្រើន ដែលរំលាយខ្លួនប្រឡូកចូលក្នុងការស្ថាបនាជាតិឬក៏ជាប់នៅក្នុងស្ថានភាពពិសេសណាមួយដូចជានៅក្នុងគុកនៅក្នុងព្រៃនៅក្នុងសមរភូមិ ឬក៏មុនពេលគេយកទៅសម្លាប់ ភ្ញាក់រឭកដល់ការចាំបាច់ និយាយបរិយាយអំពីជាតិ រៀបរៀងជាប្រយោគសំដីសំដៅ សម្ដែងឆន្ទៈប្រជាជន។ អ្នកអស់នោះ ជាអ្នកនាំពាក្យនៃការជាក់ស្ដែងមួយដែលកំពុងតែប្រយុទ្ធ៕

## ១- ច្បាប់ស្តីពីការប្រកួតប្រជែង

ច្បាប់ស្តីពីការប្រកួតប្រជែងដំបូងបំផុតត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៨៩០ នៅសហរដ្ឋអាមេរិកក្នុងគោលបំណងជំរុញឱ្យមានការប្រកួតប្រជែងផ្គត់ផ្គង់ទីផ្សារដោយស្មើភាព និងអ្នកប្រើប្រាស់ទទួលបានទំនិញដែលមានគុណភាពល្អនិងតម្លៃសមរម្យ។ក្នុងការវិវត្តបន្តមកទៀតច្បាប់ស្តីពីការប្រកួតប្រជែងត្រូវបានក្លាយទៅជាផ្នែកមួយដ៏មានសារៈសំខាន់នៃប្រពន្ធ័ច្បាប់នៅលើពិភពលោកសំរាប់ជំរុញដំណើរការប្រកួតប្រជែងផ្គត់ផ្គង់ទំនិញដែលមានគុណភាពល្អនិងតម្លៃសមរម្យលើទីផ្សារដោយស្មើភាព។

បច្ចុប្បន្នមានប្រទេសចំនួន១៣០រួមទាំងប្រទេស៩ក្នុងអាស៊ានបានរៀបចំច្បាប់ស្តីពីការប្រកួតប្រជែងសម្រាប់ការអនុវត្តន៍នៅក្នុងប្រទេសរៀងខ្លួន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ដោយការស្រាវជ្រាវ បង្កើត ផ្គត់ផ្គង់ផលិតផល ឬទំនិញដែលមានគុណភាពល្អនិងតម្លៃសមរម្យថ្មីៗ ។ ក្នុងប្រទេសកម្ពុជា ក្រសួងពាណិជ្ជកម្មបានរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។ទន្ទឹមនឹងនេះក្នុងគោលបំណងការពារអ្នកប្រើប្រាស់ពីការប្រព្រឹត្តអំពើនិងសកម្មភាពមិនសុច្ចរិតដែលរារាំងរិតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងដោយពាណិជ្ជករក្រសួងពាណិជ្ជកម្មក៏បានរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ដែលបានទទួលការអនុមតិពីរដ្ឋសភារួចមកហើយ ។

មូលដ្ឋានគតិយុត្តិនៃការតាក់តែងច្បាប់ស្តីពីការប្រកួតប្រជែងមានដូចខាងក្រោម ៖

-មាត្រា៥៦នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ ការរៀបចំនិងប្រព្រឹត្តទៅនៃប្រពន្ធ័សេដ្ឋកិច្ចនេះនឹងមានកំណត់ក្នុងច្បាប់ ។

-ព្រះរាជាណាចក្រកម្ពុជា ត្រូវគោរព និងអនុវត្តគោលនយោបាយស្តីពីការប្រកួតប្រជែងក្នុងនាមជាសមាជិក អង្គការសហប្រជាជាតិ អង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន

គួរកត់សម្គាល់ថា សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនេះ ត្រូវបានតាក់តែងឡើងដោយចំណាយពេលយូរ ។ ក្នុងឆ្នាំ២០០១ ក្រុមជំនាញការកូរ៉េខាងត្បូងបានចាប់ផ្តើមតាក់តែងសេចក្តីព្រាងច្បាប់នេះ។ ពីឆ្នាំ ២០០៦ ដល់ ២០០៧ UNCTAD បានផ្តល់ជំនួយឱ្យបន្តរៀបចំសេចក្តីព្រាងច្បាប់នេះ ។ ពីឆ្នាំ ២០១១ ដល់ ២០១២ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ជំនាញការមកជួយពិនិត្យសេចក្តីព្រាងច្បាប់នេះបន្តទៀត លុះពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ គណៈកម្មាធិការប្រកួតប្រជែងនិងអ្នកប្រើប្រាស់អូស្រ្តាលីបានជួយផ្តល់ជំនាញការពីរនាក់មកជួយពិនិត្យលើភាពខ្វះចន្លោះ។ក្រសួងពាណិជ្ជកម្មបានបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងចុងក្រោយមកទីស្តីការគណៈរដ្ឋមន្ត្រី។កិច្ចប្រជុំកម្រិតបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រីបានពិនិត្យពិភាក្សា និងបញ្ចប់ការពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ ។ កិច្ចប្រជុំកម្រិតអន្តរក្រសួងបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ដោយរក្សាជំពូកពាក់ពន្ធ័នឹងនីតិវិធីស៊ើបអង្កេត និងការកំណត់ទោសទណ្ឌជូនក្រសួងពាណិជ្ជកម្មពិភាក្សាសុំការឯកភាពពីក្រសួងយុត្តិធម៌ ។ សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនេះ នឹងត្រូវបញ្ជូនទៅសុំការអនុមតិពីរដ្ឋសភា ក្រោយទទួលបានការអនុមតិពីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ។

សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនេះ មាន ៧ជំពូក និង ៤០មាត្រា ហើយខ្លឹមសារសំខាន់នៃសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែងនេះ គឺការបង្កើតគណៈកម្មាធិការប្រកួតប្រជែងកម្ពុជាដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ពន្ធ័ដែលមានចែងនៅក្នុងជំពូកទី២ នីតិវិធីនៃការប្តឹងនិងការស៊ើបអង្កេតដែលមានចែងនៅក្នុងជំពូកទី៤ និងវិធានការផ្អាកជាបណ្តោះអាសន្ននិងសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា និងទោសបញ្ញត្តិដែលមានចែងនៅក្នុងជំពូកទី៥ និងជំពូកទី ៦។

*ក.ស.វ. - ក្រុម ២*

# ២- សេចក្តីព្រាងស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៨០ អនក្រ.បក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងដាក់ស្លាកសញ្ញាសារធាតុគីមី

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញអនុក្រឹត្យលេខ១៨០ អនក្រ.បក ដែលមានភ្ជាប់ឧបសម្ព័ន្ធ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី មានក្រសួងបរិស្ថានជាស្ថាប័នសម្របសម្រួលអនុវត្ត។ ការគ្រប់គ្រងនេះត្រូវអនុវត្តទៅលើ សម្ភារៈវេចខ្ចប់សារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់។

ចាប់ពីអនុក្រឹត្យចូលជាធរមាន ឯកសារបទដ្ឋានបច្ចេកទេសស្តីពីប្រព័ន្ធសុខដុមនីយកម្មសកល ក្នុងការចាត់ថ្នាក់និងការដាក់ស្លាកសញ្ញាសារធាតុគីមី(GHS)របស់អង្គការសហប្រជាជាតិ ដែលប្រើប្រាស់ជាឯកសារយោងសម្រាប់រៀបចំឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤នៃអនុក្រឹត្យ ក៏ត្រូវបានធ្វើបច្ចុប្បន្នកម្មផងដែរ។ ទន្ទឹមនឹងនេះ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ក៏បានរៀបចំឯកសារ ASEAN Guidance Document on Globally Harmonized System(GHS) Version 7 Implementation Alignment ឬហៅកាត់ថា ASEAN-7 ដើម្បីឱ្យមានអនុលោមភាពទៅនឹងបច្ចុប្បន្នភាពឯកសារបទដ្ឋានបច្ចេកទេស(GHS) របស់អង្គការសហប្រជាជាតិ។

ផ្អែកតាមសំណើចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលជាស្ថាប័នបង្គោលសម្របសម្រួលទំនាក់ទំនងជាមួយអាស៊ាន ក្នុងការរៀបចំនិងអនុវត្តការងារ GHS នៅក្នុងវិស័យឧស្សាហកម្មនៅព្រះរាជាណាចក្រកម្ពុជា ក្រសួងបរិស្ថានបានរៀបចំកែសម្រួលតារាង ឧបសម្ព័ន្ធចំនួន៣នៃអនុក្រឹត្យ ដើម្បីឱ្យស្របតាមគោលការណ៍សម្រាប់អនុវត្តនៅក្នុងបណ្តាប្រទេសអាស៊ានទាំង១០ ដោយមានសហការ និងបានទទួលធាតុចូលពីក្រសួងម្ចាស់សំណើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរ៉ែនិងថាមពល ក្រសួងសាធារណការនិងដឹកជញ្ជូន។

សេចក្តីព្រាងអនុក្រឹត្យថ្មីដែលត្រូវកែសម្រួល មាន៤មាត្រា គឺមាត្រា៧ មាត្រា១២ មាត្រា១៣ និងមាត្រា១៤ ដែលនៅក្នុងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤។

ខ្លឹមសារសំខាន់ៗដែលត្រូវបានកែសម្រួលក្នុងមាត្រាទាំងនេះមាន៖

-ការចាត់ថ្នាក់ភាពបង្កគ្រោះថ្នាក់ ការដាក់រូបសញ្ញានៃភាពបង្កគ្រោះថ្នាក់ និងទម្រង់គោលការណ៍នៃឯកសារព័ត៌មានអំពីសុវត្ថិភាពសារធាតុគីមី ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់

-ព័ត៌មានអំពីភាពអាចបង្កគ្រោះថ្នាក់ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមីនិងត្រូវបិទនៅលើសម្ភារៈវេចខ្ចប់

-ទម្រង់ ពណ៌ និងទំហំរបស់រូបសញ្ញានៃភាពអាចបង្កគ្រោះថ្នាក់ ដែលតម្រូវឱ្យមាននៅលើស្លាកសញ្ញាសារធាតុគីមី និងត្រូវបិទនៅលើសម្ភារៈវេចខ្ចប់

-ឯកសារព័ត៌មានអំពីសុវត្ថិភាពដែលត្រូវតែមានភ្ជាប់នឹងសារធាតុគីមីនិងផលិតផលគីមី ដែលធ្វើចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងនេះត្រូវបានដាក់ឆ្លងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២០ ក្រោមអធិបតីភាព ឯកឧត្តម **កែន សត្ថា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការចូលរួមពីឯកឧត្តម ...តំណាងក្រសួងសាមី និងសហការី ក្រសួងស្ថាប័នពាក់ព័ន្ធ និងតំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មាន ឯកឧត្តម **នៅ បោនន័រ** ឯកឧត្តម **ឆាយ ខុម** និងឯកឧត្តម **អេង រត្នមុនី**។

*ក.ស.វ. - ក្រុម ៣*

## រដ្ឋមន្ត្រីការបរទេសចិនលោក Wang Yi

រដ្ឋមន្ត្រីការបរទេសចិន លោក Wang Yi បានលើកឡើងពីសារៈសំខាន់នៃសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់កាលពីថ្ងៃអាទិត្យ បន្ទាប់ពីបញ្ចប់ដំណើរទស្សនកិច្ចទៅកាន់ប្រទេស Myanmar, Indonesia, និង Philippines។

លោក Wang Yi បាននិយាយនៅក្នុងបទសម្ភាសន៍តាមប្រព័ន្ធផ្សព្វផ្សាយថាដំណើរទស្សនកិច្ចរបស់លោកទៅកាន់ប្រទេស Myanmar បានផ្ញើសារយ៉ាងច្បាស់ថា ប្រទេសចិនមានឆន្ទៈក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅនូវការប្រាស្រ័យទាក់ទងនិងពង្រឹងការសម្របសម្រួលជាមួយប្រទេសជិតខាង ហើយនឹងគាំទ្រដល់ដំណើរការរបស់រដ្ឋាភិបាលថ្មីរបស់ Myanmar ។

រដ្ឋមន្ត្រីការបរទេសរូបនេះបាននិយាយថា ប្រទេសទាំងពីរគួរតែខិតខំប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត COVID-19បង្កើតរបៀងសេដ្ឋកិច្ចគាំទ្រការព្រួយបារម្ភរបស់គ្នាទៅវិញទៅមកនិងជំរុញកិច្ចសហប្រតិបត្តិការក្នុងតំបន់។

លោក Wang Yi ក៏បានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងរួមគ្នាជាមួយ Myanmar នៅក្នុងកិច្ចសហប្រតិបត្តិការ Lancang-Mekong និងច្រករបៀងសេដ្ឋកិច្ច China-Myanmar ។

នៅពេលសួរអំពីការរំពឹងទុករបស់លោកចំពោះកិច្ចសហប្រតិបត្តិការChina-Indonesiaក្នុងយុគសម័យក្រោយការរាតត្បាត លោក Wang Yi បានលើកឡើងពីគំរូ ៣ ដែលភាគីទាំងពីរសម្រេចបានក្នុងដំណើរទស្សនកិច្ចរបស់លោក គឺគំរូនៃកិច្ចសហប្រតិបត្តិការវ៉ាក់សាំង គំរូនៃការស្ថាបនាខ្សែក្រវាត់និងផ្លូវរួមគ្នា និងគំរូនៃការការពារពហុភាគីនិយម។

ចំពោះទំនាក់ទំនង China-Brunei លោក Wang Yi បានលើកឡើងពីខួបលើកទី ៣០ នៃការបង្កើតទំនាក់ទំនងការទូត រវាង China និង Brunei និងខួបលើកទី ៣០ នៃទំនាក់ទំនងសន្ទនាអាស៊ាន-ប្រជាជាតិចិន ដែលជាឱកាសប្រទេសចិនដើម្បីតម្រឹមគោលដៅរយៈពេលវែងរបស់ខ្លួនជាមួយ Wawasan របស់ប្រទេសប្រ៊ុយណេ ២០៣៥ ។

ក្នុងឱកាសនៃខួបលើកទី ៣០ ទ្វេភាគីលោក Wang Yi បាននិយាយថា ប្រទេសចិននិងប្រ៊ុយណេបានព្រមព្រៀងគ្នាដើម្បីធ្វើកិច្ចសហប្រតិបត្តិការក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅ។លោកសម្តែងក្តីសង្ឃឹមថាប្រ៊ុយណេអាចផ្តល់តួនាទីយ៉ាងពេញលេញក្នុងតួនាទីជាប្រធានអាស៊ានជំរុញទំនាក់ទំនងចិន-អាស៊ានឱ្យឈានដល់កម្រិតថ្មីមួយ និងដឹកនាំកិច្ចសហប្រតិបត្តិការអាស៊ីបូព៌ាផ្តោតលើអាស៊ីបូព៌ាការអភិវឌ្ឍន៍និងសមាហរណកម្មតំបន់។

ដោយរំលឹកដំណើរទស្សនកិច្ចរបស់លោកទៅកាន់ប្រទេសហ្វីលីពីនលោករដ្ឋមន្ត្រីការបរទេសបានសង្កត់ធ្ងន់លើកិច្ចសហប្រតិបត្តិការលើវ៉ាក់សាំងការពារ Covid-19 ការស្តារសេដ្ឋកិច្ច និងបញ្ហាសមុទ្រចិនខាងត្បូង។

លោកក៏បានសង្កត់ធ្ងន់ផងដែរអំពីចំណងមិត្តភាពចិន-អាស៊ានក្នុងដំណើរទស្សនកិច្ចរបស់លោកដោយនិយាយថា ទំនាក់ទំនងគឺមានភាពស្វាហាប់និងមានផ្លែផ្កាក្នុងចំណោមដៃគូសន្ទនារបស់អាស៊ានជាមួយនឹងអត្ថប្រយោជន៍ជាក់ស្ដែងដែល បានផ្ដល់ដល់ប្រជាជនចំនួន ២ ពាន់លាននាក់នៅក្នុង ១១ ប្រទេស។

លោកWangYiគូសបញ្ជាក់ពីចំណងមិត្តភាពចិន-អាស៊ានអំពាវនាវឱ្យមានកិច្ចសហប្រតិបត្តិការបន្ថែមទៀត។

លោក Wang Yi បាននិយាយថា ដំណើរទស្សនកិច្ចនេះមានគោលបំណងដើម្បីចាប់យកឱកាសរួមគ្នាជាមួយថ្នាក់ដឹកនាំនៃប្រទេសទាំង៤និងអគ្គលេខាធិការអាស៊ានដើម្បីបង្កើតនូវភាពជាដៃគូយុទ្ធសាស្ត្រខ្ពស់រវាងចិននិងអាស៊ាននិងកសាងសហគមន៍ចិន-អាស៊ានដែលមានអនាគតរួមគ្នា។

បច្ចុប្បន្ននេះស្ថានភាពក្នុងតំបន់និងអន្តរជាតិកំពុងស្ថិតក្នុងដំណាក់កាលច្របូកច្របល់និងផ្លាស់ប្ដូរ។ លោកWangYiបាននិយាយថាទាំងចិននិងអាស៊ានជឿថាដើម្បីធានាបាននូវសន្តិភាពនិងវិបុលភាពយូរអង្វែងនៅអាស៊ីប៉ូពាំពហុភាគីនិយម ពិតប្រាកដត្រូវតែមានការគាំទ្រនិងអនុវត្ត៕

ដោយ នរ៉ាណាឫទ្ធិ អាននន្ទជាយ៉ាត

**គំនិតគួរពិចារណា**

« កំណាញ់និងការឱ្យទាន សេចក្ដីសុខនិងសេចក្ដីទុក្ខ ស្រឡាញ់និងស្អប់
បុគ្គលអាចយកប្រមាណសេចក្ដីបាន ដោយយកខ្លួនអាត្មាជាគ្រឿងឧបមា។ »

ស្រីហិតោបទេស - ភិក្ខុ ប៉ាង ខាត់ វិរិយបណ្ឌិតោ ១៩៥៤

# ការវិវត្តនៃប្រព័ន្ធទឹកសាប និងប្រវត្តិនៃវិស័យជលផលទឹកសាបកម្ពុជា (ត)

នៅឆ្នាំ១៩៣៩ អាជ្ញាធរបានដកសិទ្ធិពីសម្បទានិកចុងក្រោយមួយឈ្មោះ **ទាម៉េង**[25] ដែលកាន់កាប់ដែននេសាទភាគខាងជើងឈៀងលិចនៃបឹងទន្លេសាប (ខេត្តសៀមរាបនិងខេត្តកំពង់ធំ) ដើម្បីលប់បំបាត់ការរកស៊ីផ្តាច់មុខទាំងស្រុង។ ក្នុងការធានាលំនឹង និងនិរន្តរភាពវិស័យនេសាទ, រដ្ឋបាលអាណានិគមបារាំងបានប្រមូលផ្តុំព័ត៌មានវិទ្យាសាស្ត្រនិងបទពិសោធន៍នៃការដាក់កំហិតនិងបទបញ្ជាដែលបានដាក់ឲ្យប្រតិបត្តិតាមកន្លងមក សម្រាប់ជាមូលដ្ឋានដល់ការធ្វើពង្រាងច្បាប់នេសាទ ដែលត្រូវ គ្របដណ្តប់ទៅលើទិដ្ឋភាពទាំង៤ នៃប្រព័ន្ធគតិយុត្តិៈ (១) សិទ្ធិប្រើប្រាស់ធនធានជលផលដែននេសាទរៀបជាពួកដែលត្រូវដាក់ឲ្យដេញថ្លៃកន្លែងនេសាទបំរុងទុកនិងកន្លែងហាមឃាត់ការនេសាទ (២) បទបញ្ជានេសាទដែលក្នុងនោះមានកំណត់ពេលរដូវធ្វើនេសាទប្រភេទនិងសមាសភាពនៃតំបន់ ដែលចាត់ចែងទុកសម្រាប់ធ្វើអ្វីមួយ លក្ខខ័ណ្ឌសម្បទានតាមរយៈកិច្ចសន្យាឬការបើកឲ្យដេញថ្លៃជាសាធារណៈ កាតព្វកិច្ចរបស់សម្បទានិក ឧបករណ៍ និងរបៀបនេសាទហាមឃាត់ លក្ខខ័ណ្ឌនៃការនេសាទគ្រួសារលក្ខខ័ណ្ឌនៃការនេសាទសិប្បកម្មឬខ្នាតមធ្យមការកំណត់ព្រំសីមាដែននេសាទបំរុងទុក មធ្យោបាយការពារទំនាស់ ការផ្តល់កំរៃលើកទឹកចិត្តដល់អ្នកផ្តល់ព័ត៌មានពីការនេសាទល្មើសវិធានការណ៍ពិសេសចាំបាច់សម្រាប់ការពារ និងការធ្វើអាជីវកម្មសមស្រប (៣) ការប្រព្រឹត្ត ល្មើស និងការដាក់ទោស (៤) ឈុតច្បាប់ និងការវិនិច្ឆ័យទោស។ សេចក្តីព្រាងច្បាប់នេះត្រូវបានធ្វើចប់សព្វគ្រប់ នៅឆ្នាំ១៩៤០ (P. Chevey et F. Le Poulin, 1939; P. Chevey et F. Le Poulin, 1940) ដោយយកបទបញ្ជាមកអនុវត្តជាបន្តបន្ទាប់ជាការដកពិសោធន៍នៅពេលរង់ចាំការអនុម័តដើម្បីទប់ស្កាត់ភាពអសកម្ម។ ទោះជានៅដើមរជ្ជកាលព្រះបាទនរោត្តមសីហនុ (គ្រងរាជ្យនៅឆ្នាំ១៩៤១) ដែលជាប់វិករក្នុងសង្គ្រាមលោកលើកទី២ និងព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យអស់ជាង១០ឆ្នាំក៏ដោយ ក៏ការធ្វើអង្កេត និងការប្រមូលទិន្នន័យផលនេសាទនៅតែបន្តធ្វើ។ ដោយផ្អែកតាមលទ្ធផលស្រាវជ្រាវរបស់ នាវាស្រាវជ្រាវផងនោះ ផលនេសាទជាលក្ខណៈសេដ្ឋកិច្ចទូទាំងប្រទេស ដែលគួរឲ្យទុកចិត្តត្រូវបាន ប៉ាន់ស្មានថាមានចំនួនប្រហែល១២០០០០តោន នៅរដូវនេសាទ ១៩៣៩-៤០ (P. Chevey et F. Le Poulin, 1940)។

នៅឆ្នាំ១៩៤២ ក្នុងគោលបំណងគ្រប់គ្រងការរកស៊ីជួញដូរ និងការនាំចេញត្រីឲ្យបានល្អនោះ រាជការបានសាកល្បងបង្កើតសហករណ៍ពាណិជ្ជកម្មត្រីកែច្នៃដែលចាត់ចែងដោយអ្នកជំនួញជាតិខ្មែរជំនួសឈ្មួញចិនទាំងអស់ តែដោយសារគ្មានបទពិសោធន៍ និងជំនាញក្នុងការរកស៊ីជួញដូរនាំចេញផងនោះ របរនេះត្រូវបានប្រែត្រឡប់ទៅនៅក្រោមដៃឈ្មួញកណ្តាលចិនវិញដដែលនៅប៉ុន្មានឆ្នាំក្រោយមក (Kierman, Ben, and Chanthou Boua, 1982)[26] ។

---

[25] សម្បទានិកដែលកាន់អាជ្ញាប័ណ្ណគ្រប់គ្រងដែននេសាទខេត្តសៀមរាបនិងកំពង់ធំ ក្រោយឆ្នាំ១៩០៧រហូតមកដល់ឆ្នាំ១៩៣៩ (ទីតាំងនៅបារាយខេត្តកំពង់ធំ)

[26] Kierman, Ben, and Chanthou Boua (eds) 1982. Peasants and Politics in Kampuchea 1942-81. London: Zed Press.

ទិន្នន័យផលនេសាទនៅតែជាប្រធានបទក្តៅគគុកដដែលនៅក្នុងទសវត្សឆ្នាំ៤០ រវាងក្រុមអ្នកជំនាញបារាំង ដែលក្នុងនោះ លោក M. Krempf ថាផលនេសាទមានដល់ទៅ៤១០,០០០តោន នៅរដូវនេសាទ ១៩៤៨-១៩៤៩តែត្រូវបានបដិសេដដោយលោកLamasson1949[27] ព្រោះថានៅពេលនោះត្រីកែច្នៃនាំចេញមានចំនួនត្រឹមតែ៣៨,០០០តោន/ឆ្នាំ ប៉ុណ្ណោះ (Henri Brenier, 1950)[28] ។

## ៥.ស្ថានភាពវិស័យនេសាទទឹកសាបក្នុងអន្តរកាលពីអាណានិគមបារាំងមកដើមសម័យកាលព្រះរាជាណាចក្រកម្ពុជា

ការវិវត្តរបស់វិស័យនេសាទពីឆ្នាំ១៩៤៥ដល់១៩៥៥ អាចចាត់ទុកថាជាដំណាក់កាលអន្តរកាលដ៏សំខាន់មួយដែលមានជាប់ទាក់ទងទៅនឹងព្រឹត្តិការណ៍ជាច្រើនដូចជាសង្គ្រាមប្រទាញប្រទង់គ្នារវាងអាណានិគមបារាំងនិងជប៉ុននៅចុងសង្គ្រាមលោកលើកទី២ ការបញ្ចប់សង្គ្រាមលោកលើកទី២ និងការបង្កើតអង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៥តាមសន្ធិសញ្ញាអន្តរជាតិដែលតម្រូវឲ្យប្រទេសអាណានិគមទាំងអស់ត្រូវផ្តល់ឯករាជ្យទៅឲ្យបណ្តាប្រទេសនៅក្រោមអាណានិគមរបស់ខ្លួន ឲ្យក្លាយទៅជារដ្ឋឯករាជ្យពេញលេញ ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ និងការផ្ទេរឯករាជ្យជាដំណាក់កាលមកឲ្យកម្ពុជា និងការរៀបចំបង្កើតស្ថាប័នរដ្ឋសំខាន់ៗ (នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ) និងការអនុម័តរដ្ឋធម្មនុញ្ញ និងបទដ្ឋានគតិយុត្តិសំខាន់ៗទាក់ទងទៅនឹងការរៀបចំប្រព័ន្ធរដ្ឋបាលសម្រាប់ការគ្រប់គ្រងរដ្ឋជានិតិរដ្ឋ (ដែលជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើជាក្បួនខ្នាតកំណត់តម្រឹម ស្វ័យត្រួតពិនិត្យ និងទប់ស្កាត់ភាពអសកម្ម និងការឃុបឃិតនៅក្នុងការប្រព្រឹត្តទៅនៃស្ថាប័នរដ្ឋ) និងច្បាប់ និងបទបញ្ជាផ្សេងៗទៀតសម្រាប់ស្ថាប័នរដ្ឋតាមវិស័យចំណុះស្ថាប័ននីតិប្រតិបត្តិ អនុវត្តមុខងារ និងភារកិច្ច ដែល តម្រូវទៅតាមលំនាំរដ្ឋបាលប្រទេសបារាំង ដែលរដ្ឋបាលអាណានិគមបានផ្ទេរមក( សាយ បូរី ១៩៩៨)។

ទន្ទឹមគ្នានេះដែរក៏មានការរកឃើញថ្មីមួយអំពីផលិតភាពនិងការបន្តពូជពង្សដ៏សម្បើមនៃត្រីប្រា (Pangasionodon hypophthalmus) ក្នុងប្រព័ន្ធទឹកសាបកម្ពុជា ដោយត្រីតែមួយប្រភេទនេះ បានគ្របដណ្តប់ដល់ទៅ១/៣នៃផលនេសាទទឹកសាបសរុបទូទាំងប្រទេស (Blanc M., 1959)[29] ដែល លក្ខខណ្ឌពិសេសនេះអាចប្រហែលជាមានការជាប់ទាក់ទងជាមួយវត្តមាននៃប្រភេទត្រីនេះនៅក្នុងប្រព័ន្ធទឹកសាប និងវារីវប្បកម្មនៃប្រទេសថៃនិងឥណ្ឌូនេស៊ីដែលរហូតមកដល់ពេលនេះនៅពុំទាន់អាចរកបានព័ត៌មានបញ្ជាក់អំពីរឿងនេះនៅឡើយ ។យ៉ាងណាក៏ដោយក៏ទល្ងីករណ៍វិទ្យាសាស្ត្រនៃការសិក្សាស្រាវជ្រាវអំពីវដ្តជីវិតត្រីប្រាដែលបានធ្វើបទបង្ហាញ និងបានពិភាក្សាវែកញែកយ៉ាងល្អិតល្អន់ ទូលំទូលាយជាមួយអ្នកជំនាញត្រីឆ្មាក្នុងតំបន់នៅក្នុងសន្និសិទស្តីពីត្រីឆ្មាអាស៊ី ចុងក្រោយនៅទីក្រុងបូហ្គ័រ ប្រទេសឥណ្ឌូណេស៊ី កាលពីខែឧសភាឆ្នាំ២០០២ បានបញ្ជាក់យ៉ាងច្បាស់ថាត្រីប្រាគឺជាត្រីឆ្មាទំហំធំមួយប្រភេទដែលមានប្រភពដើមនិងវដ្តជីវិតនៅទន្លេមេគង្គកំណាត់ខាងក្រោមល្បាក់ខោនប្រាកដមែន (Tana, T.S., 2002)[30] ។ដោយត្រីប្រាជាត្រីស៊ីចំណីចំរុះ ហើយអាចសំរបខ្លួនរស់នៅបានទៅតាមស្ថានភាពប្រែប្រួលនៃបរិស្ថាននិងភាពសម្បូរបែបរបស់វាផងនោះត្រីនេះត្រូវបានក្លាយទៅជាជំរើសមួយ សម្រាប់កិច្ចអភិវឌ្ឍបច្ចេកវិជ្ជាវារីវប្បកម្មនាសម័យនោះ ដែលធ្វើឲ្យត្រីនេះត្រូវបានគេនាំយកទៅប្រទេសខាង លើនោះជាលក្ខណៈឯកជនដើម្បីសាកល្បងចិញ្ចឹមដោយគ្មានការកត់ត្រាត្រឹមត្រូវឡើយ ដែលយូរៗទៅព័ត៌មានពិតប្រាកដត្រូវរលប់បាត់បន្តិចម្តងៗរហូតដល់បាត់ដានទាំងស្រុងនៅក្នុងសង្គមនោះទៅ។

---

27 LEMASSON, J., 1949. Conservateur des Eaux et Foret. Publication: Le Service de la Peche en Indochine (Institut des Recherche Piscicoles).

28 Congres des Peches et des Pecheries dans l'Union Francaise d'Outre-mer, October, 1950. Consisting: (1) BRENIER Henri, 1950. L'Institut Oceanographique de l'Indochine; (2) DURAND, J., 1950. L'Elevage du Chanos-chanos sur les Cotes d'Annam; (3) LAFONT, R., 1950. L'Industrie du Nuoc-mam au Cambodge; (4) LAFONT, R., 1950. Formes d'Utilisation pour l'Alimentation des Produits de la Peche dans des Eaux Continentales du Cambodge; (5) LAFONT, R., 1950. La Graisses de Poisson du Cambodge; (6) SERENE, R., 1950. Huitres d'Indochine et Ostreiculture dans le Sud-Annam.

29 BLANC Maurice, 1959. Considerations biogeographiques sur la faune itchyologique des eaux douces du Cambodge. Seance du 18 Juin 1959.

30 Tana, T. S., 2002. Life Cycle of Pangasionodon hypophthalmus, a dominant Mekong Catfish. Proceeding of Catfish Asia Conference 2002 (Bogor, Indonesia).

ដំណាក់កាលដំបូងនៃព្រះរាជាណាចក្រកម្ពុជាឯករាជ្យវិស័យនេសាទនៅតែជាវិស័យសេដ្ឋកិច្ចដ៏សំខាន់មួយ ដែលអ្នកនយោបាយធំៗតែងតែលើកយកមកជជែកវែកញែក ដើម្បីធានានិរន្តរភាព។

ដូច្នេះសេចក្តីព្រាងច្បាប់នេសាទឆ្នាំ១៩៤០ត្រូវបានលើកយកមកពិនិត្យឡើងវិញដោយមានការកែលំអខ្លះៗ ឲ្យស្របទៅតាមស្ថានភាពសេដ្ឋកិច្ចនយោបាយនៃសង្គមថ្មី ដែលក្នុងនោះ រយៈពេលកាន់កាប់ឡូត៍នេសាទ៣ឆ្នាំ ដែលដេញថ្លៃបានម្តងៗ ត្រូវបានកែមកជា២ឆ្នាំវិញ។ ទោះជាបានរៀបចំយ៉ាងនេះក៏ដោយ ក៏កំណើនប្រជាជនពីចំនួន ៣.៧៤៨.០០០នាក់ នៅឆ្នាំ១៩៤៨ (ដែលកើនឡើងដល់ចំនួន ៤.០៧៤.០០០នាក់ នៅឆ្នាំ១៩៥០ រួចកើនដល់ចំនួន ៤.៣៥៩.០០០នាក់ នៅឆ្នាំ១៩៥៦) កើនដល់ ចំនួន ៤.៧៤០.០០០នាក់ នៅឆ្នាំ១៩៥៨ (Blanc M., 1958) នៅតែជាបញ្ហាប្រឈមរវាងការនេសាទជាប់ពន្ធ និងការនេសាទគ្រួសារ នៅក្នុងការបែងចែកផលប្រយោជន៍នៃធនធានជលផលនេះ។

## ៦. វិស័យនេសាទទឹកសាបក្នុងសម័យសង្គមរាស្ត្រនិយម

នៅឆ្នាំ១៩៥៥ ព្រះមហាក្សត្រព្រះបាទនរោត្តមសីហនុ បានផ្ទេររាជ្យសម្បត្តិថ្វាយព្រះបិតា ព្រះអង្គព្រះបាទនរោត្តមសុរាម្រិត ដើម្បីចុះមកដឹកនាំរាជរដ្ឋាភិបាលតាមគោលបយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិឲ្យបានខ្លាំងក្លា។ក្នុងគោលបំណងគ្រប់គ្រងវិស័យនេសាទឲ្យមានប្រសិទ្ធិភាពនោះរាជរដ្ឋាភិបាលបានយកសេចក្តីព្រាងច្បាប់ និងបទបញ្ជានៅឆ្នាំ១៩៤០ ដែលបានកែសម្រួលហើយនោះ មកអនុម័តនិងដាក់ឲ្យអនុវត្តនៅឆ្នាំ១៩៥៦។ ផលនេសាទត្រូវបានប៉ាន់ស្មានថាមាន១៣០,០០០តោន នៅរដូវនេសាទ១៩៥៦-៥៧ (Bardach, 1957)[31] សម្រាប់ជាមូលដ្ឋានវាយតម្លៃសេដ្ឋកិច្ចនេសាទ និងការប្រមូលចំណូលពន្ធ។

បច្ចេកវិទ្យានេសាទថ្មី (ខ្សែអំបោះនីឡុងនិងសាច់អួននីឡុងនិងម៉ាស៊ីនកាណូតដែលផលិតនៅប្រទេសជប៉ុន) ត្រូវបាននាំចូលតាមរយៈប្រទេសថៃឡង់ដ៍ យកមកប្រើនៅក្នុងវិស័យនេសាទទឹកសាប នៅឆ្នាំ១៩៦០ (តំបូងប្រើនៅក្នុងការនេសាទដាយតាមដងទន្លេសាប ហើយក្រោយមកក៏រីករាលដាល ទៅបឹងទន្លេសាបនិងកន្លែងផ្សេងៗទៀតទូទាំងប្រទេស)[32]។នៅអំឡុងឆ្នាំ១៩៦៣-៤ឧបករណ៍មងចាប់ត្រីត្រូវបាននាំចូលយកមកប្រើក្នុងដែលនេសាទទឹកសាប ដូចគ្នានឹងខ្សែនីឡុងនិងសាច់អួនឬសំណាញ់ នីឡុងដែរ។ នៅឆ្នាំ១៩៦៤-៦៦ រោងចក្រត្បាញមង-អួន ២កន្លែងនៅភ្នំពេញ ត្រូវបានបង្កើតដោយប្រើ វត្ថុធាតុដើមជាខ្សែអំបោះនីឡុងពីជប៉ុនតាមរយៈប្រទេសថៃឡង់ដ៍ ដើម្បីបំពេញតម្រូវការក្នុងស្រុក។

នៅគ្រាដំបូងនាយកដ្ឋានគង្គា, រុក្ខាប្រមាញ់ និងនេសាទ ដែលបង្កើតនៅក្រោមក្រសួងកសិកម្ម នៅក្រោយពេលកម្ពុជាទទួលបានឯករាជ្យមកនោះ ត្រូវទទួលអនុវត្តច្បាប់នេសាទ និងត្រូវរៀបចំកសាងធនធានមនុស្ស ដើម្បីអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាពនាពេលអនាគត ដោយត្រូវជ្រើសរើសសិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាចំណេះទូទៅឲ្យប្រឡងចូលរៀនវគ្គជំនាញគ្រប់គ្រងបច្ចេកទេសនិងរដ្ឋបាលដើម្បីបំពេញការងារជាមន្ត្រីរាជការ និងជាបុគ្គលិករបស់នាយកដ្ឋាននេសាទ។ បន្ទាប់មកទៀត ដោយបានពិនិត្យឃើញថា វិស័យនេសាទមានចារិតលក្ខណៈស្មុគស្មាញនៅក្នុងប្រព័ន្ធយុត្តាធិការជាតិដែលទាមទារឲ្យមានការគ្រប់គ្រងក្នុងរបៀបដោយឡែកនោះ (ការយល់ឃើញរបស់ក្រុមតិចណូក្រាដ) នាយកដ្ឋាននេសាទត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៣ ដាច់ចេញពីនាយកដ្ឋានគង្គា រុក្ខាប្រម៉ាញ់ និងនេសាទ ខណៈក្រុមមន្ត្រីរាជការ និងបុគ្គលិកចាស់ និងជ្រើសរើសថ្មីបានបញ្ចប់ វគ្គបណ្តុះបណ្តាលជំនាញ (ក្របខណ្ឌរដ្ឋបាល អនុរក្ស និងត្រួតពិនិត្យ) ត្រូវបានផ្ទេរនិងចាត់តាំងឲ្យ បំពេញមុខងារ និងភារកិច្ចក្នុងវិស័យនេសាទជារហូតមក។ តាមការកត់សំគាល់ ចាប់តាំងពីមានការដាក់កំហិត និងបទបញ្ជានេសាទជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៤០មក ផលនេសាទ១២០០០០តោន/ឆ្នាំ

---

31 Bardach, J., 1959. Fisheries in Cambodia.

32 ប្រភពៈ លោកប៊ុត ផុន ដង្ហៅនេសាទដាយដែលបានយកខ្សែនីឡុងមកចាក់ធ្វើដាយចាប់ត្រីតំបូងគេនៅឆ្នាំ១៩៦០ (សម្ភាសន៍ផ្ទាល់មាត់នៅឆ្នាំ១៩៨៣)។

ហាក់ដូចជានៅតែមានស្ថិរភាពជាប់ជារហូតដល់ឆ្នាំ១៩៧០ លើកលែងតែនៅឆ្នាំ១៩៦១ ដែលផលត្រីបានធ្លាក់ចុះប្រហែល២០%ដែលធ្វើឲ្យរាជរដ្ឋាភិបាលសម្រេចលប់ឡូត៍សម្រាប់នៅបឹងទន្លេសាបជាង១០កន្លែង មិនឲ្យធ្វើនេសាទ ដោយកំណត់ដាក់កន្លែងទាំងនោះ ឲ្យទៅជាកន្លែងនេសាទបំរុងទុកវិញ ហើយបង្កើតឡូត៍ឆ្នេរខ្សាច់ចំនួន២០កន្លែង នៅតាមដងទន្លេមេគង្គក្នុងខេត្តកំពង់ចាម និងកណ្ដាល និងឡូត៍ដាយបង្កង ចំនួន ១៣ជួរ នៅតាមដងទន្លេតូចក្នុងខេត្តព្រៃវែងជាបន្ថែមវិញ។

មានការស្រាវជ្រាវមួយទៀតនៅអំឡុងឆ្នាំ១៩៦១-៦៣ បានឲ្យដឹងថាផលត្រីចាប់បានមានចំនួន ១២០០០តោន/ឆ្នាំហើយត្រីកែច្នៃចំនួន៥៣ាន់តោន/ឆ្នាំត្រូវបាននាំចេញតាមច្រកកំពង់ផែកំពង់សោមងត្រីរស់នាំចេញតាមផ្លូវទឹកទៅវៀតណាមនៅដដែល (FILLY, M. et d'AUBENTON, F., 1963)[33] ។

ទន្ទឹមគ្នានេះដែរនៅអំឡុងឆ្នាំ១៩៦១-៦៣ មានការស្រាវជ្រាវមួយពីដំណើរកករដីល្បាប់ដែលទន្លេមេគង្គនាំទៅចាក់ចូលបឹងទន្លេសាបជារៀងរាល់ឆ្នាំ ដើម្បីស្រាយកង្វល់មួយ ដែលថាបឹងទន្លេសាប នឹងត្រូវរីងរាក់គោកនៅពេលឆាប់ៗខាងមុខ។លទ្ធផលស្រាវជ្រាវបានបញ្ជាក់ថាការកេដីល្បាប់នេះអាចធ្វើឲ្យបឹងទន្លេសាបគោកបាននៅ១៤០០ឆ្នាំខាងមុខឬយ៉ាងហោចណាស់ក៏៥០០ឆ្នាំដែរនៅក្នុងករណីដែលអាចមានការហូរច្រោះខ្លាំង នាំយកកករដីល្បាប់ចាក់ចូលទៅក្នុងបឹងទន្លេសាប ដោយសារការបាត់ បង់ព្រៃឈើច្រើននៅតំបន់រងទឹកភ្លៀងនៅផ្នែកខាងលើ (Carbonel et Guiscafre,1963)[34] ។

ច្បាប់នេសាទនាពេលនោះបានហាមប្រាមហាមឃាត់មិនឲ្យនេសាទត្រីបីប្រភេទ៖ ត្រីរាជ ត្រីគល់រាំង និងត្រីត្រសក់ ក្នុងគោលបំណងអភិរក្សត្រីដែលគិតថាជិតបាត់បង់ពីក្នុងធម្មជាតិដោយពុំទាន់ ដឹងពីជីវសាស្ត្ររបស់វាពិតប្រាកដ ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាភ្ញាស់បង្កាត់ដាក់បញ្ចូលទៅក្នុងធម្មជាតិវិញ ដែលធ្វើឲ្យកិច្ចអភិរក្សនេះ ហាក់ពុំសូវទទួលបានការចាប់អារម្មណ៍ពីអ្នកនេសាទទូទៅប៉ុន្មានឡើយ។ ជាក់ស្ដែង ស្ទើរតែពុំដែលមានអ្នកនេសាទមួយរាយការណ៍ពីការចាប់បានត្រីទាំងនោះឡើយ ដូចជានៅដើមឆ្នាំ១៩៦៤ អ្នកនេសាទឈ្មោះ **ភារស្សូរ**[35] ចាប់បានត្រីគល់រាំង(៦០-១០០គក្រ/ក្បាល)រាប់រយក្បាល ទម្ងន់រាប់តោន នៅតាមដងទន្លេប្រឡាយមាសខេត្តកំពង់ឆ្នាំងហើយបានលក់ចេញទៅឲ្យឈ្មួញកែច្នៃសម្រាប់នាំចេញដោយមិនបានរាយការណ៍ និងមិនមានសមត្ថកិច្ចណាមួយហាមឃាត់ឡើយ។

ការគ្រប់គ្រងវិស័យនេសាទតាមច្បាប់នេសាទឆ្នាំ១៩៥៦អាចចាត់ទុកថាបានប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវនៅឆ្នាំ១៩៦៩ដោយមាន ការចូលរួមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ (Tan Kim Huon, 1969)[36] ។ ជាសំខាន់គឺទំនាស់ទាក់ទងទៅនឹងការបែងចែកផលប្រយោជន៍នៃធនធានធម្មជាតិ ត្រូវបានសម្របសម្រួលយ៉ាងល្អតាមច្បាប់កំណត់ និងការយល់អធ្យាស្រ័យគ្នាទៅវិញទៅមករវាងថៅកែឡូត៍នេសាទ និងសហគមមូលដ្ឋាន ទោះជាចំនួនប្រជាជនបានកើនឡើងពីចំនួន ៤.៣៥៩.០០០នាក់ នៅឆ្នាំ១៩៥៦ ទៅដល់ចំនួន ៤.៧៤០.០០០នាក់ នៅឆ្នាំ១៩៥៨ (Blanc, M., 1958) ហើយកើនឡើងដល់ចំនួន ៥.៧៤៦.០០០នាក់ នៅឆ្នាំ១៩៦២ រួចកើនឡើងទៅដល់ចំនួន ៧លាននាក់ នៅឆ្នាំ១៩៦៩ (ស្ថិតិជាតិឆ្នាំ១៩៧០) ក៏ដោយ ។

## ៧. វិស័យនេសាទទឹកសាបសម័យសាធារណរដ្ឋ

ក្នុងរបបសាធារណរដ្ឋកម្ពុជាសង្គ្រាមបានកើតឡើងពាសពេញប្រទេសដែលបង្ខំឲ្យមន្ត្រីរដ្ឋការទាំងអស់ដែលក្នុងនោះក៏មានមន្ត្រីរដ្ឋការនេសាទផងដែរដែលត្រូវមកប្រមូលផ្ដុំរស់នៅធ្វើការនៅទីក្រុងភ្នំពេញវិញក៏ប៉ុន្តែ

33 FILY, M. et d'AUBENTON, F., 1963. Cambodge: Grand-lac - Tonle Sap, Technologie des Peches 1962-63. Published under scientific patronage of the Museum d'Histoire Naturelle de paris.

34 Carbonel and Guiscafre, 1963. Sedimentology of the Mekong and Tonle Sap lake.

35 លោកភារស្សូរ ជាប្រធានអង្គភាពនេសាទរដ្ឋកណ្ដាលស្ទឹង(១៩៨០-១៩៨៣) នឹងជាអតីតថៅកែឡូត៍នេសាទលេខ៤ ខ្សាច់ស្ដែននិងលេខ៦ស្ទឹងជ្រៅ ខេត្តកំពង់ឆ្នាំង នៅអំឡុងឆ្នាំ១៩៦២-៧០ ជាអ្នកផ្ដល់ពត៌មាន។

36 Tan Kim Huon, 1969. The Compile of Fisheries Law

ការនេសាទនៅកន្លែងដែលមានសន្តិសុខដូចជានៅបឹងទន្លេសាប នៅតែមាន សកម្មភាពដដែល។ ត្រីកែឆ្អៃត្រូវបានដឹកតាមទូកកាណូតតូចៗពីបឹងទន្លេសាបមកខេត្តកំពុងឆ្នាំងនិងត្រូវដឹកបន្តតាមក្បួនទូកដឹកទំនិញធំៗដែលត្រូវបានការពារដោយកងទ័ពជើងទឹកទៅភ្នំពេញ។ ការនាំចេញ ទាំងត្រីរស់ និងទាំងត្រីកែឆ្អៃត្រូវបានបញ្ចប់ទាំងស្រុងនៅឆ្នាំ១៩៧០។នៅឆ្នាំ១៩៧៤សង្គ្រាម កាន់តែបង្កើនសកម្មភាព ជាពិសេសនៅតាមផ្លូវគមនាគមន៍ទាំងគោកទាំងទឹក ធ្វើឲ្យការដឹកជញ្ជូនត្រីកែច្នៃពីបឹងទន្លេសាបមកភ្នំពេញត្រូវធ្វើតាមផ្លូវអាកាសវិញ (ក្រគរ-ភ្នំពេញ)។

នៅអំឡុងឆ្នាំ១៩៧០-៧១ ក្រុមនិស្សិតដែលឆ្លងកាត់ការបំពាក់បំប៉នជំនាញជាអនុរ័ក្ស និងជាអ្នកត្រួតពិនិត្យនេសាទថ្នាក់មធ្យម(Controlleur)បានបញ្ចប់ហើយចេញធ្វើកម្មសិក្សាតែនៅក្នុងក្រុងភ្នំពេញព្រោះមិនអាចចុះតាមខេត្តបាន ហើយត្រូវបានដាក់បញ្ចូលក្របខណ្ឌនៅឆ្នាំបន្ទាប់ ដូចគ្នានឹងនិស្សិតដែលសិក្សានៅមហាវិទ្យាល័យនេសាទនៃសកលវិទ្យាល័យភូមិន្ទកសិកម្មថ្នាក់វិស្វករវគ្គតំបូងក៏ដូចជាវគ្គចុងក្រោយនៅសម័យនោះ ដែលបានបញ្ចប់ការសិក្សានៅឆ្នាំ១៩៧២ ហើយចុះធ្វើកម្មសិក្សានៅតែក្នុងទីក្រុងភ្នំពេញក៏ត្រូវបានបញ្ចូលក្របខណ្ឌនៅឆ្នាំ១៩៧៣ដែរ។ក្នុងចំណោមមន្ត្រីវិស្វករថ្មីៗទាំងនោះមានមួយចំនួនដែលមានលទ្ធភាពបានទៅបន្តការសិក្សានៅប្រទេសបារាំង ព្រោះតែសង្គ្រាម បានកំហិតពួកគេ មិនអាចឲ្យបំពេញការងារជំនាញត្រឹមត្រូវនៅក្នុងស្រុកបាន។ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនេសាទដែលរួមទាំងធនធានមនុស្សដែលបានបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវផងនោះ ត្រូវបានបញ្ចប់ ទាំងស្រុងនៅឆ្នាំ១៩៧៥។

## ៨. វិស័យនេសាទទឹកសាបក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ការនេសាទនៅកន្លែងនេសាទសំខាន់ៗនៅទូទាំងប្រទេស ត្រូវបានរបបកម្ពុជាប្រជាធិបតេយ្យរៀបចំឲ្យដំណើរការវិញ ដើម្បីផ្គត់ផ្គង់ត្រីដល់អង្គភាពសំខាន់ៗ និងកងទ័ព។ ប្រជាជនទាំងមានជំនាញនេសាទ ទាំងគ្មានជំនាញត្រូវបានអង្គការខ្មែរក្រហម បញ្ជូនពីចេញពីសហករណ៍នានា ឲ្យទៅនេសាទត្រី និងកែឆ្អៃត្រីនៅបឹងទន្លេសាប និងកន្លែងនេសាទផ្សេងៗទៀត។ទោះជាយ៉ាងនេះក៏ដោយ ក៏ប្រជាជន នៅតែខ្វះខាតត្រីសម្រាប់បរិភោគដដែល ហើយអ្នកដែលនៅឆ្ងាយពីបឹង ទន្លេ ស្ទឹង គឺស្ទើរតែមិនដែល បានត្រីបរិភោគផង ដែលបង្ហាញឲ្យឃើញពីភាពទន់ខ្សោយឬការមិនយកចិត្តទុកដាក់ដល់ការចែកចាយឬការបែងចែកផលប្រយោជន៍នៃធនធានធម្មជាតិសមស្របឲ្យបានដល់គ្រប់គ្នា។ ក្រៅពីការធ្វើនេសាទ និងកែឆ្អៃត្រី អង្គការខ្មែរក្រហមពុំបានធ្វើអ្វីដែលទាក់ទងទៅនឹងការគ្រប់គ្រងធនធានមច្ឆជាតិ ដែលរួមមាន ការគ្រប់គ្រងរដ្ឋបាល ការអភិរក្សធនធាន និងការអភិវឌ្ឍឡើយ ព្រោះរបបនេះមិនមានការយល់ដឹងពីកិច្ចអភិរក្សធនធានធម្មជាតិ និងចាត់ទុកប្រព័ន្ធរដ្ឋបាលទាំងអស់ជាប្រព័ន្ធការិយាធិបតេយ្យ ជិះជាន់ពុករលួយ។

ជាការចម្លែកទៅទៀតនោះ គឺមានការនេសាទសម្លាប់សត្វផ្សោតរាប់រយក្បាលនៅបឹងទន្លេសាប នៅរដូវប្រាំងឆ្នាំ១៩៧៦ ដើម្បីចម្រាញ់យកខ្លាញ់ចាក់ម៉ាស៊ីនកាណូត ព្រោះតែការផ្គត់ផ្គង់ប្រេងម៉ាស៊ីន កាណូតនេសាទមិនគ្រប់គ្រាន់ (ពត៌មានពីប្រធានក្រុមនេសាទឈ្មោះ តាំងឡាយ ដែលនៅពេលនោះ បានទទួលបញ្ជាឲ្យដេញបាញ់ផ្សោតយកទៅចម្រាញ់យកខ្លាញ់នៅកំពង់ឃ្លាំងខេត្តសៀមរាប)[37] ។

## ៩. ការវិវត្តនៃវិស័យនេសាទ (ជលផល) ទឹកសាបនៅសហសម័យ

ក្រោយរបបខ្មែរក្រហមភ្លាម ធនធានមច្ឆជាតិបានដើរតួយ៉ាងសំខាន់បន្ទាប់ពីស្រូវ នៅក្នុងការផ្គត់ផ្គង់ម្ហូបអាហារដល់ប្រជាជនខ្មែរដែលកំពុងខ្វះខាតស្បៀងអាហារ។ត្រីទឹកសាបសម្បូរណាស់នៅពេលនោះទោះជាមិនទាន់មានឧបករណ៍សំភារៈនេសាទគ្រប់គ្រាន់ក៏ដោយក៏ប្រជាជនភាគច្រើនអាចចាប់ ឬដោះដូរត្រីមកបរិភោគ

[37] លោកតាំងឡាយ ជាប្រធានក្រុមសាមគ្គីឡូត៍នេសាទមួយនៅខេត្តសៀមរាមនៅអំឡុងទសវត្សឆ្នាំ៨០ បច្ចុប្បន្នរស់នៅអូស្ត្រាលី (ពត៌មានទទួលបានពីឯ.ឧ. ណៅធួក ជាអតីតប្រធានការិយាល័យជលផលខេត្តសៀមរាប ១៩៧៩-៩៨ អគ្គនាយកជលផល ១៩៩៨-២០១៥ បច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងកសិកម្ម)។

បានជាបង្គួរដែរ។ក្នុងស្ថានភាពដ៏លំបាកនៅក្នុងសង្គមសេដ្ឋកិច្ចកម្ពុជាដែលខ្វះខាតអ្វីៗគ្រប់យ៉ាងទាំងអស់នោះ ធនធានត្រីទឹកសាបបានបង្ហាញពីសក្តានុពលជាកម្លាំងចលកររបស់ខ្លួនក្នុងការជំរុញវិស័យកសិកម្ម ដែលជាមូលដ្ឋានស្បៀងជាតិ និងវិស័យផ្សេងៗទៀតឲ្យមានដំណើរការធម្មតាឡើងវិញយ៉ាងលឿនក្នុងអំឡុង៣-៤ ឆ្នាំក្រោយមក។

## ៩.១. ការស្តារប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនេសាទ (ជលផល) ទឹកសាបឡើងវិញ

នៅដើមឆ្នាំ១៩៧៩ វិស័យនេសាទត្រូវបានស្តារឡើងវិញភ្លាមៗ ជាមួយវិស័យកសិកម្មក្នុងនាម "វិស័យជលផល"ដើម្បីបំពេញសេចក្តីត្រូវការស្បៀងជាចាំបាច់។នាយកដ្ឋានជលផលត្រូវបានបង្កើតនៅក្រោមក្រសួងពាណិជ្ជកម្មដើម្បីធ្វើនេសាទផ្គត់ផ្គង់ត្រីដល់មន្ត្រីរដ្ឋការនិងបុគ្គលិកនៅគ្រប់ស្ថាប័នរដ្ឋនៅទូទាំងប្រទេស ។ ភារកិច្ចនេះតម្រូវឲ្យនាយកដ្ឋានជលផល បង្កើតអង្គភាពនេសាទរដ្ឋចំនួន១២ នៅតាមខេត្តដែលមានដែននេសាទទឹកសាបសំខាន់ៗ និងក្រុមហ៊ុនជលផលមួយ សំរាប់ប្រមូលទិញ ផលនេសាទរស់ ស្រស់ និងកែឆ្នៃដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការក្នុងប្រទេសនិងនាំចេញទៅវៀតណាម។ក្រុមហ៊ុនជលផលបាននាំចេញត្រីដំរីស្រស់ ក្លាសេ និងអណ្តើករស់ ទៅវៀតណាមចំនួនរាប់រយតោនក្នុង មួយឆ្នាំៗ ចាប់ពីឆ្នាំ១៩៨២ ដល់១៩៩៣ ដោយនាំចូលមកវិញនូវសំភារៈបរិក្ខារនេសាទដូចជាម៉ាស៊ីនកាណូតដែលជាបន្ទាប់មកបានបង្វែរទៅជាការនាំចេញត្រីដំរីរស់ទៅហុងកុង តៃវាន់ និងសឹង្ហបូរីវិញ។ ឯ ការនាំចេញត្រីរស់តាមទូកឌុក (ទូកដឹកជញ្ជូនត្រីរស់) និងបៃរ (ទ្រុងឈើបណ្តែតទឹកចល័តសំរាប់ចិញ្ចឹម ត្រីនិងដឹកជញ្ជូនត្រីរស់) ចំនួនរាប់ពាន់តោនទៅវៀតណាម ត្រូវបានឈ្នួញអនុវត្តជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ១៩៨១ ដល់ឆ្នាំ១៩៩៣ ទើបមានការប្រែប្រួល ដោយសារតែមានការប្រកួតប្រជែងជាមួយផ្សារនៅប្រទេសថៃរួមផ្សំនឹងការបើកច្រកផ្លូវគោក (ប៉យប៉ែត) ផង និងការធ្លាក់ចុះផលនេសាទផង ។

រោងចក្រតម្បាញមង-អួនទាំងពីរក៏ត្រូវបានដាក់ឲ្យដំណើរការឡើងវិញដែរដោយប្រើប្រាស់វត្ថុធាតុដើម (ខ្សែអំបោះនីឡុង) ពីសហភាពសូវៀត ដែលជាប្រភពផ្តល់ជំនួយធំជាងគេនៅពេលនោះ។

វិស័យជលផលត្រូវបានរដ្ឋាភិបាលចាត់ទុកថាជាមុខព្រួញសេដ្ឋកិច្ចដ៏សំខាន់មួយ ដូចផលិតកម្មកៅស៊ូ ដែលត្រូវផ្តល់ឥណទានពីធនាគាររដ្ឋមុនគេបង្អស់នៅពេលចាប់ផ្តើមដំណើរការចាយលុយរៀលឡើងវិញជាដំបូងនាដើមឆ្នាំ១៩៨១។ របរនេសាទទឹកសាបនៅគ្រប់កន្លែងនេសាទ ត្រូវបានស្តារឡើងវិញយ៉ាងឆាប់រហ័ស នៅឆ្នាំ១៩៨១-២តាមការបង្កើតក្រុមសាមគ្គីនេសាទជាច្រើនដើម្បីធ្វើនេសាទនៅតាមកន្លែងនេសាទដែលធ្លាប់មានពីសម័យមុនមក។ អង្គភាពកងកម្លាំងប្រដាប់អាវុធ ក៏បានបង្កើត អង្គភាពនេសាទរៀងៗខ្លួនដែរ ដែលក្នុងនោះ អង្គភាពកងទ័ពជាតិ និងនគរបាលជាតិធ្វើអាជីវកម្មឡូត៍នេសាទនៅតំបន់បឹងទន្លេសាប ដើម្បីផ្គត់ផ្គង់ត្រីដល់កងកម្លាំងប្រដាប់អាវុធ និងនគរបាល។ ឯអង្គភាពកងទ័ពវៀតណាម ក៏បានធ្វើនេសាទអួនសម្រុង និងកែឆ្នៃត្រីនៅបឹងទន្លេសាបផងដែរ ដើម្បីផ្គត់ផ្គង់កងទ័ពរបស់ខ្លួនដែលឈរជើងនៅកម្ពុជានិងនាំទៅវៀតណាម (ការនេសាទនេះចាប់បានត្រីធំៗជាច្រើនជាពិសេសត្រីរាជត្រីគល់រាំងនិងត្រីក្រសក់រាប់ពាន់ក្បាលនិងត្រីផ្សេងទៀតរាប់រយតោនក្នុងមួយឆ្នាំៗ) រហូតដល់ឆ្នាំ១៩៨៩ ទើបឈប់ ព្រោះកងទ័ពវៀតណាមត្រូវដកត្រឡប់ទៅស្រុកវិញ។នៅពេលនោះអាជ្ញាធរក្រុងភ្នំពេញក៏មានអង្គភាពនេសាទដាយត្រីមួយដែរដែលនៅដំណើរការរហូតដល់សព្វថ្ងៃនេះ។

ការនាំចេញត្រីរាជស្រស់ដោយលួចលាក់ទៅប្រទេសថៃបានចាប់ផ្តើមដំណើរការឡើងវិញនៅប្រហែលអំឡុងពាក់កណ្តាលទសវត្សឆ្នាំ១៩៨០ ដោយការពន្លះសាច់ត្រីជាដុំៗប្រឡាក់អំបិលតិចតួច ដើម្បីបំបាត់ក្លិនប្រ៉េមរួចដាក់ក្នុងធុងក្លាសេទឹកកក ហើយដឹកជញ្ជូនតាមរថយន្តឆ្លងកាត់ព្រំដែនចូលទៅប្រទេសថៃ។ ត្រីរាជទាំងអស់ដែលចាប់បានដោយអួនសម្រុងនិងដាយត្រីតាមដងទន្លេសាបត្រូវបានប្រោះទុកឲ្យនៅរស់រហូតដល់មានឈ្នួញផ្តាច់មុខមួយមកប្រមូលទិញនាំចេញ។ក្រោយឆ្នាំ២០០០ទើបមានអ្នកនេសាទខ្លះៗបានរាយការណ៍

ពីត្រីរាជដែលចាប់បាន ហើយបានដោះលែងទៅក្នុងធម្មជាតិវិញ។

នៅចុងឆ្នាំ១៩៨០ នាយកដ្ឋានជលផល ត្រូវបានផ្ទេរពីក្រសួងពាណិជ្ជកម្ម ឲ្យទៅនៅក្រោមក្រសួងកសិកម្មវិញហើយជាបណ្តើរៗបានប្រែក្លាយខ្លួនពីការធ្វើនេសាទដោយខ្លួនឯងផ្ទាល់ឲ្យទៅជាស្ថាប័នគ្រប់គ្រងរដ្ឋបាលវិស័យជលផលវិញ។ នៅអំឡុងឆ្នាំ ១៩៧៩-៨១ មន្ត្រីវិស្វករ គ្រូគពិនិត្យ និងអនុរក្សនេសាទ ដែលបានទទួលការបណ្តុះបណ្តាលពីសម័យមុនសង្គ្រាមដែលនៅរស់មួយចំនួនបានចូលមកបម្រើការងារនៅនាយកដ្ឋាននិងការិយាល័យជលផលខេត្ត-ក្រុងនៅទូទាំងប្រទេសហើយចាប់ផ្តើមរៀបចំការងារគ្រប់គ្រងរដ្ឋបាលតាមច្បាប់និងបទបញ្ញាឡើងវិញ(អង្គភាពនេសាទរដ្ឋត្រូវកាត់បន្ថយជាបន្តបន្ទាប់ចាប់ពីចំនួន១២នៅឆ្នាំ១៩៧៩-៨០មកនៅចំនួន៩នៅឆ្នាំ១៩៨៥ ហើយចុះមកនៅ ត្រឹម៧នៅឆ្នាំ១៩៨៧)។ នៅដើមទសវត្សឆ្នាំ៩០អង្គភាពនេសាទរដ្ឋ នៅមានចំនួន៥ ហើយចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០១៤ អង្គភាពនេសាទរដ្ឋនៅសល់តែចំនួន៣ប៉ុណ្ណោះ។ ការដែលគួរឲ្យកត់សំគាល់ មួយនៅឆ្នាំ១៩៨១ គឺការនេសាទកូនត្រីប្រា ដែលដឹកនាំធ្វើដោយពួកអ្នកនេសាទវៀតណាម នៅអំឡុងខែកក្កដា-កញ្ញាដោយឧបករណ៍ដាយស្បៃមុង នៅកំណាត់ទន្លេមេគង្គក្រោម ចាប់ពីអ្នកលឿងទៅដល់ព្រំប្រទល់កម្ពុជា-វៀតណាមនិងនៅតាមដងទន្លេតូចដើម្បីត្រងចាប់កូនត្រីប្រាដែលទើបនឹងញាស់ហើយអណ្តែតតាមខ្សែទឹកពីតំបន់មេគង្គខាងលើក្នុងខេត្តស្ទឹងត្រែងនិងក្រចេះ។កូនត្រីប្រាដែលចាប់បានត្រូវដឹកតាមទូកឌុកយកទៅថែបំប៉នឲ្យធំនៅវៀតណាម ហើយលក់ទៅឲ្យវារីវប្បករ ដើម្បីដាក់ចិញ្ចឹមក្នុងបែរ ឬស្រះ។ ការនេសាទកូនត្រីប្រាត្រូវបានហាមឃាត់ដាច់ខាតកាលពីសម័យមុនៗ ព្រោះវាប៉ះពាល់ខ្លាំងបំផុតដល់ផលស្តុកត្រីប្រានិងប្រភេទត្រីផ្សេងៗទៀតដែលពងកូននៅតំបន់ខាងលើហើយកូនត្រីដែលញាស់បានអណ្តែតតាមខ្សែទឹកចូលទៅក្នុងបឹងទន្លេសាបនិងទំនាបមកក្រោមដើម្បីស៊ីចំណីនិងរីកធំធាត់នៅរដូវវស្សា។ការនេសាទកូនត្រីប្រានេះគឺជាមុខរបរដ៏កាក់កបថ្មីមួយរបស់អ្នកនេសាទនិងអ្នកចិញ្ចឹមត្រីនៅវៀតណាមនៅពេលនោះដោយពួកគេអាចចាប់កូនត្រីប្រាដែលមានអាយុពី១០ទៅ១៥ថ្ងៃបានរាប់ពាន់លានកូនត្រីក្នុងមួយរដូវហើយអាចចិញ្ចឹមបានផលរាប់ម៉ឺនតោនជារៀងរាល់ឆ្នាំ។ នៅឆ្នាំ១៩៩១ ការនេសាទកូនត្រីប្រានេះបានរីករាលដាលទៅដល់ទន្លេមេគង្គភាគខាងលើទន្លេចតុមុខ ដែល៦-៧ឆ្នាំ ក្រោយមកទិន្នផលកូនត្រីប្រាបានធ្លាក់ចុះយ៉ាងខ្លាំង ធ្វើឲ្យការនេសាទនេះត្រូវបានផ្អាកដោយស្វ័យប្រវត្តិនៅឆ្នាំ១៩៩៩។ ទន្ទឹមគ្នានឹងការធ្លាក់ចុះនេះ បច្ចេកវិទ្យាភ្ញាស់បង្កាត់ ផលិតកូនត្រីប្រាដោយសិប្បនិមិត្ត ត្រូវបានអ្នកវិទ្យាសាស្ត្របារាំងធ្វើការអភិវឌ្ឍបានជោគជ័យនៅវៀតណាម(Phillips Cacot, 1998)[38] ដែលជាបន្ទាប់កបច្ចេកវិទ្យានេះ ត្រូវបានគេប្រើប្រាស់ផលិតកូនត្រីប្រាដើម្បីបំពេញសេចក្តីត្រូវការរបស់វារីវប្បករវៀតណាមភាគខាងត្បូងដែលជំនួសការចាប់កូនត្រីប្រាធម្មជាតិបានទាំងស្រុងនៅឆ្នាំ២០០២។

នៅដើមឆ្នាំ១៩៨៣ការសិក្សាស្រាវជ្រាវពីស្ថានភាពសេដ្ឋកិច្ចនៃឡូត៍នេសាទបឹងព្រែកនៅបឹងទន្លេសាបខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល និងឡូត៍នេសាទដាយនៅខេត្តកណ្តាល ដែលកាន់កាប់ ដោយអង្គភាពរដ្ឋ និងនៃការនេសាទអួនសម្រុងងនៅបឹងទន្លេសាបដែលអនុវត្តដោយអង្គភាពនេសាទ កងទ័ពវៀតណាម ត្រូវបានដឹកនាំធ្វើដើម្បីអាចបានជាមូលដ្ឋានសម្រាប់កំណត់តម្លៃដាក់ឲ្យដេញថ្លៃឡូត៍នេសាទនាពេលខាងមុខ (ទូច ស៊ាងតាណា ១៩៨៣)[39] ។

ការអភិវឌ្ឍធនធានមនុស្សត្រូវបានធ្វើឡើងជាតំបូងតាមការជ្រើសរើសមន្ត្រីជលផល និងនិស្សិតមួយចំនួនដើម្បីផ្តល់អាហារូបករណ៍ឲ្យទៅសិក្សាជំនាញជលផលថ្នាក់បឋមមធ្យមនិងឧត្តមនៅប្រទេសវៀតណាម

38 Philippe Cacot, 1998. Description of the sexual cycle related to the environment and set up of the artificial propagation in Pagasius bocourti (Sauvage, 1880) and  Pagasionodon hypophthalmus (sauvage, 1878), reared in the floating cages and in ponds in the Mekong Delta. Proceeding of the Mid-term Workshop of the "Catfish Asia Project", Cantho, Vietnam 1998.

39 ទូចស៊ាងតាណា, ១៩៨៣. ការស្រាវជ្រាវពីស្ថានភាពសេដ្ឋកិច្ចនៃឡូត៍នេសាទលេខ២ខេត្តកំពុងធំ, ឡូត៍នេសាទលេខ៤, ៦, ១០, ១៤ និង១៨ខេត្តកំពុងឆ្នាំង, ឡូត៍នេសាទលេខ ១០ និងឡូត៍នេសាទដាយជួរលេខ៨ និង៩ខេត្តកណ្តាល។

នៅអំឡុងឆ្នាំ១៩៨៥ និង១៩៨៦។ ជាមួយគ្នានេះដែរ ក៏មាននិស្សិតខ្លះបានទៅ សិក្សាជំនាញជលផលសមុទ្រនៅបណ្តាប្រទេសអឺរ៉ុបខាងកើតដែរ។

ក្រិត្យច្បាប់និងបទបញ្ជាជលផលដែលចម្លងស្ទើរតែទាំងស្រុងពីច្បាប់និងបទបញ្ជានេសាទឆ្នាំ១៩៥៧ ដោយគ្រាន់តែសម្របសម្រួលទៅតាមរបបនយោបាយសេដ្ឋកិច្ចសង្គមនិយមនាពេលនោះ ត្រូវបានព្រាងចប់សព្វគ្រប់ហើយដាក់ឲ្យអនុម័តនៅឆ្នាំ១៩៨៧និងចូលជាធរមានបញ្ញត្តិនៅឆ្នាំ១៩៨៩។ច្បាប់កំណត់បង្កើតឡូត៍នេសាទបួនប្រភេទឡើងវិញសម្រាប់ដាក់ឲ្យដេញថ្លៃជាសាធារណៈចាប់ពីឆ្នាំ១៩៩០-៩១(តារាងលេខ១)ហើយដែននេសាទដែលត្រូវការពារសម្រាប់ការនេសាទសិប្បកម្មដែលត្រូវមានលិខិតអនុញ្ញាតិនិងជាប់ពន្ធក៏ត្រូវបានបើកទូលាយឲ្យពលរដ្ឋដាក់ពាក្យសុំធ្វើនេសាទដែរ។ដែននេសាទសម្រាប់ការនេសាទគ្រួសារ និងដែននេសាទបំរុងដែលហាមឃាត់រាល់ការនេសាទ ទាំងអស់ត្រូវបានកំណត់ព្រំសីមាយ៉ាងត្រឹមត្រូវ។ ត្រីរាជ ត្រីគល់រាំង និងត្រីត្រសក់នៅតែជាប្រភេទត្រីហាមឃាត់មិនឲ្យចាប់តែនៅតែគ្មានប្រសិទ្ធិភាពព្រោះការអនុវត្តច្បាប់នៅមានភាពធូររលុង។

### តារាងលេខ១. ឡូត៍នេសាទដែលត្រូវបានរៀបចំចាត់ចែងដើម្បីដាក់ឲ្យដេញថ្លៃសម្រាប់រយៈពេល២ឆ្នាំម្តង

| តំបន់ | ឡូត៍នេសាទបឹងព្រែក | ឡូត៍នេសាទដាយ | ឡូត៍ដាយបង្កង | ឡូត៍ឆ្នេរខ្សាច់ |
|---|---|---|---|---|
| បឹងទន្លេសាប+ដងទន្លេសាប | ៥៧ | ៦១ | ០ | ០ |
| ទន្លេមេគង្គលើ | ២៤ | ០ | ០ | ៣២ |
| ទន្លេមេគង្គក្រោម | ៥៩ | ០ | ១៣ | ២ |
| សរុប | ១៤០ | ៦១ | ១៣ | ៣៤ |

( ប្រភព: នាយកដ្ឋានជលផល)

នៅឆ្នាំ១៩៨៥ការនាំចេញត្រីកែស និងត្រីក្រាយក្លាសេទឹកកកដឹកតាមទូកនេសាទសមុទ្រទៅប្រទេសថៃរាប់ពាន់តោនក្នុងមួយឆ្នាំៗត្រូវបានចាត់ចែងដោយឈ្មួញមួយចំនួនរហូតដល់ការផ្គត់ផ្គង់ត្រីប្រភេទនេះបានធ្លាក់ចុះខ្លាំងនៅឆ្នាំ១៩៩៣ដោយត្រីមួយចំនួនធំត្រូវបាននាំចេញផ្លូវគោកតាមច្រកប៉យប៉ែត ខេត្តបាត់ដំបង។ ការនាំចេញត្រីដំរីរស់តាមយន្តហោះទៅសិង្ហបុរី ហុងកុង និងម៉ាឡេស៊ីបានចាប់ផ្តើមនៅអំឡុងឆ្នាំ១៩៩១ (ត្រូវបានបញ្ចប់នៅជាងដប់ឆ្នាំក្រោយមក ដោយសារការផ្គត់ផ្គង់ពីធម្មជាតិ បានធ្លាក់ចុះស្ទើរដាច់ពូជ) ។

ការដែលគួរឲ្យចាប់អារម្មណ៍មួយទៀត គឺការនាំចេញកូនក្រពើដ៏គគ្រឹកគគ្រេងទៅប្រទេសថៃនៅឆ្នាំ១៩៨៨-៩៣ដោយសារកូនក្រពើឡើងថ្លៃដល់២០០ដុល្លាអាមេរិកក្នុងមួយក្បាលដែលជំរុញឲ្យការចិញ្ចឹមក្រពើមានការរីកចម្រើនយ៉ាងខ្លាំង។ទោះជាមានការលំបាកខ្លះៗនៅអំឡុង២ទសវត្សចុងក្រោយនេះដោយសារតម្លៃកូនក្រពើបានធ្លាក់ចុះជាបន្តបន្ទាប់រហូតមកនៅត្រឹម១០ដុល្លាអាមេរិកក្នុងមួយក្បាលនាបច្ចុប្បន្ននេះក៏ដោយក៏មុខរបរនេះនៅតែមានអត្ថិភាពដដែល។

នៅអំឡុងឆ្នាំ១៩៨៧-៨៩ ការស្រាវជ្រាវវិទ្យាសាស្ត្រមួយដឹកនាំធ្វើដោយអ្នកជំនាញវៀតណាម ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានជលផលទឹកសាប បានរកឃើញត្រីទឹកសាបជាង២០០ប្រភេទនៅពេល នោះ (Tan, N. X., Hao, N. V., Chong, N. V., Ngeu, M. and Leu, T. T., 1991)[40] ។

40 Tan, N. X., Hao, N. V., Chong, N. V., Ngeu, M. and Leu, T (1991): Report on the freshwater fishery resources survey in Cam¬bodia.

កិច្ចអភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេសត្រូវបានធ្វើឡើងតាមការប្រឡងជ្រើសរើសនិស្សិតឲ្យចូលរៀនយកជំនាញជលផលនៅសកលវិទ្យាល័យកសិកម្មចំការដូង និងសាលាមធ្យមបច្ចេកទេស កសិកម្មព្រែកលាភ ដើម្បីបំពេញភារកិច្ចក្នុងវិស័យជលផលចាប់ពីឆ្នាំ១៩៨៧មក។

ជាលើកតំបូងនៅក្នុងប្រវត្តិរបស់វិស័យជលផលកម្ពុជាដែលមានមន្ត្រី២រូប ត្រូវបានជ្រើសរើសឲ្យទទួលអាហារូបករណ៍អន្តរជាតិ ដើម្បីទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតវិទ្យាសាស្ត្រជលផលនៅវិទ្យាស្ថានបច្ចេកវិទ្យាអាស៊ី ( AIT ) នៅប្រទេសថៃឡង់ដ៍ នៅអំឡុងឆ្នាំសិក្សា១៩៩១-៩៣។

នៅក្នុងដំណាក់កាលនេះដែរ ផលនេសាទទូទាំងប្រទេសដែលកត់ត្រាបានជាមធ្យម មានចំនួន ៦០,០០០តោន/ឆ្នាំ ស្មើនឹង៥០% នៃផលនេសាទនៅអំឡុងទសវត្សឆ្នាំ៦០ ដែលអ្នកជំនាញបានវាយតម្លៃថា អ្នកនេសាទជាប់ពន្ធនៅតែលាក់បាំងផលនេសាទពិតដដែល ព្រោះពួកគេដឹងថាព័ត៌មាននេះ នឹងអាចជាប់ទាក់ទងទៅនឹងការកំណត់អត្រាពន្ធនេសាទ។

### ៩.២. វិស័យជលផលនៅសម័យព្រះរាជាណាចក្រទីពីរ

ក្រោយការបោះឆ្នោតសកលនៅឆ្នាំ១៩៩៣ជំនួយអន្តរជាតិជាច្រើនបានសំរុកចូលមកជួយអភិវឌ្ឍវិស័យជលផលនៅគ្រប់ផ្នែកដូចជាការអភិវឌ្ឍន៍វារីវប្បកម្ម ការវាយតម្លៃផលស្តុកជលផល ការអភិវឌ្ឍន៍ធនធានមនុស្ស ការពង្រឹងសហគមនេសាទ ការធ្វើសេចក្តីព្រាងច្បាប់ជលផលថ្មីជាដើម។

ស្ថិតិជលផលផ្លូវការនៅតែរក្សា ផលត្រីទឹកសាបក្នុងចន្លោះ៦០,០០០ទៅ៧០,០០០ពាន់តោន ដដែលរហូតដល់ឆ្នាំ២០០០ដែលខុសប្លែកគ្នាពីលទ្ធផលស្រាវជ្រាវដែលដឹកនាំធ្វើដោយគ្រោងការស្រាវជ្រាវនេសាទទឹកសាបកម្ពុជា( ឆ្នាំ១៩៩៤-១៩៩៧ )ក្រោមការឧបត្ថមទុនពីប្រទេសដាណឺម៉ាក់និងគណៈកម្មាការទន្លេមេគង្គដែលបានរកឃើញថាផលនេសាទទឹកសាបមានប្រហែល ១៣០,០០០តោន ទៅ១៨០,០០០តោន/ឆ្នាំ[41]។ ទោះជាយ៉ាងនេះក៏ដោយ ក៏បរិមាណផលស្តុកនេះ បានបង្ហាញអំពីការធ្លាក់ចុះយ៉ាងគំហុកនៃប្រភេទត្រីប្រា ពីភាពសម្បូរលើសលប់ជាងគេ កាលពីពាក់កណ្តាលសតវត្សមុន មកនៅត្រឹមតែ៣ភាគរយនៅឆ្នាំ២០០០ និងនៅតិចជាង១ភាគរយនាបច្ចុប្បន្ននេះ។ជាមួយគ្នានេះដែរការនាំចេញត្រីកេសនិងត្រីក្រាយស្រស់រាប់រយតោនទៅប្រទេសថៃតាមសមុទ្រក៏ត្រូវបានបង្វែរទៅតាមផ្លូវគោកតាមច្រកប៉យប៉ែតខេត្តបាត់ដំបងវិញដែរ។ឯត្រីស្រស់ផ្សេងទៀត និងត្រីកំភ្លាញប្រឡាក់អំបិល ហើយហូតឆ្អឹងរាប់ពាន់តោន ក៏ត្រូវបាននាំចេញតាមច្រកនេះផងដែរ។

ការអភិវឌ្ឍន៍ធនធានមនុស្សទាំងនៅក្នុងនិងក្រៅប្រទេសលើគ្រប់កំរិតជំនាញ ដែលក្នុងនោះ អាហារូប-ករណ៍អន្តរជាតិទៅសិក្សាថ្នាក់បណ្ឌិតវិទ្យាសាស្ត្រជាតំបូង នៅប្រទេសដាណឺម៉ាក់នាឆ្នាំ១៩៩៧ និងជាបន្តបន្ទាប់មកនៅប្រទេសជប៉ុន ត្រូវបានផ្តល់ទៅឲ្យមន្ត្រីជលផលមួយចំនួនដើម្បីអាចឈានទៅដល់ការបង្កើតវិទ្យាស្ថានស្រាវជ្រាវមួយនៅឆ្នាំ២០០១ ( Van Zalinge, N.P.,T. Nao, Tana, T.S. and L. Deap, 2000 )[42] ។

#### ៩.២.១. ស្ថានភាពសេដ្ឋកិច្ចជលផល

ដំណាក់កាលអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យទាន់សភាពការណ៍សេដ្ឋកិច្ចពិភពលោកវិស័យជលផលដែលជាវិស័យអាទិភាពមួយនោះបានបង្ហាញចេញនូវភាពស្រពិចស្រពិលឆ្លងកាត់តាមការរួមចំណែកដ៏តិចតួចស្តួចស្តើងនៅក្នុងចំណូលរដ្ឋ ( ពន្ធមិនមែនសារពើពន្ធ ) ដែលធ្វើឲ្យមហាជនមានការចង់ដឹងអំពី ស្ថានភាព និងតុល្យភាព

---

41 Van Zalinge, N.P., T. Nao, Tana, T.S. and L. Deap, 1999. Cambodian Freshwater Fish Catch Assessment 1994-97.

42 Van Zalinge, N.P., T. Nao, Tana, T.S. and L. Deap, 2000. Where there is water, there is fish? Cambodian Fisheries issues in a Mekong River Basin perspective.

សេដ្ឋកិច្ចជលផលកាន់តែខ្លាំងឡើងៗរហូតដល់មានការសិក្សាស្រាវជ្រាវមួយដែលរៀបចំធ្វើឡើងនៅក្នុងអំឡុងឆ្នាំ១៩៩៨-៩ ដើម្បីបំពេញនិក្ខេបបទថ្នាក់បណ្ឌិតវិទ្យាសាស្ត្ររបស់អ្នកនិពន្ធ[43]។ ការស្រាវជ្រាវនេះ បានផ្តោតទៅលើការចំណាយវិនិយោគនិងការចំណាយធ្វើប្រតិបត្តិការនេសាទជាលក្ខណៈសេដ្ឋកិច្ចដែលជាប់កាតព្វកិច្ចបង់ពន្ធទាំងអស់សម្រាប់ជាមូលដ្ឋានវិភាគសេដ្ឋកិច្ចជលផលទឹកសាបទូទាំងប្រទេស។ លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថា ដោយសារការកំហិត របស់ច្បាប់ជលផល ទោះជាមកដល់ឆ្នាំ១៩៩៨ហើយក៏ដោយ ក៏ការនេសាទអចល័តនៅទឹកសាប នៅតែរក្សាបច្ចេកទេសនេសាទបែបបុរាណរបស់ខ្លួនបានដដែល លើកលែងតែប្រភេទនេសាទដាយ និងនេសាទចល័តប៉ុណ្ណោះ ដែលឃើញមានការប្រើបច្ចេកវិទ្យាថ្មីៗជាច្រើន។ យ៉ាងណាក៏ដោយ ក៏គេឃើញថាមានឡូត៍នេសាទនៅតំបន់ខ្លះៗ បានកែប្រែប្រើសាច់អួនជំនួសព្រួលឬស្សីជាបណ្តើរៗហើយដែរ។

ការអង្កេតបានរកឃើញថា នៅក្នុងការចំណាយទៅលើទ្រព្យសកម្មថេររបស់អង្គភាពនិមួយៗនៃបណ្តាប្រភេទនេសាទ ការចំណាយទៅលើសំបកទូក និងម៉ាស៊ីនរបស់អង្គភាពឡូត៍នេសាទនិមួយៗ នៅតំបន់បឹងទន្លេសាបក្តាប់យកជាង៦០%នៃចំណាយលើទ្រព្យសកម្មថេរសរុបហើយក៏មានកំរិតខ្ពស់ជាងការចំណាយរបស់អង្គភាពឡូត៍នេសាទនៅតំបន់ផ្សេងៗទៀតដែរ ដែលអាចបង្ហាញថាអង្គភាពនេសាទ ឡូត៍បឹងទន្លេសាបត្រូវការមធ្យោបាយទូក កាណូតម៉ាស៊ីនច្រើនជាងតំបន់ផ្សេងទៀតទាំងអស់ ដើម្បីធ្វើសកម្មភាពឲ្យមានប្រសិទ្ធិភាពនៅលើដែននេសាទដ៏ធំទូលំទូលាយ។ ឯការចំណាយលើសំភារៈនេសាទ ជាផលអនុផលព្រៃឈើដូចជាបង្គោលឈើធំៗដែលអាចប្រើបាន២ទៅ៣ឆ្នាំក៏ឃើញនៅមានកំរិតខ្ពស់ឯការចំណាយទៅលើខ្សែអំបោះនីឡុងខ្សែពួរនីឡុង និងលោហធាតុ សម្រាប់ធ្វើជាឧបករណ៍នេសាទ ក៏នៅមានកំរិតទាបនៅឡើយនៅពេលនោះ។ ការប្រើប្រាស់ប្រេងឥន្ធនៈ មានភាពខុសគ្នាច្រើនណាស់រវាងការនេសាទចល័ត (ច្រើនជាង៣០%) និងការនេសាទអចល័ត (តិចជាង៨%)។ ការចំណាយទៅលើមធ្យោបាយធ្វើដំណើរ និងដឹងជញ្ជូន (ទូក ម៉ាស៊ីន) បានក្តាប់យកប្រហែលពី ៣% ទៅ៧% នៃ ចំណាយសរុប។ ឯការចំណាយទៅលើពលកម្មប្រហែល២ទៅ៣ម៉ឺននាក់ដែលក្នុងនោះ៣០%ជាពលកម្មមិនអចិន្ត្រៃយ៍ បានស្រូបយកប្រហែលពី២៦%ទៅ៣៧%នៃចំណាយសរុបផងដែរ។

ការស្រាវជ្រាវក៏បានរកឃើញទៀតថាការធ្វើអាជីវកម្មនេសាទទឹកសាបជាលក្ខណៈសេដ្ឋកិច្ចគ្រប់ប្រភេទនៅកម្ពុជា ទាំងការធ្វើនេសាទនៅតាមឡូត៍នេសាទ ទាំងការធ្វើនេសាទសិប្បកម្មចល័ត និងអចល័ត គឺជាការវិនិយោគទុនរយៈកាលខ្លីដែលអង្គភាពនេសាទនិមួយៗបានប្រើប្រាស់ទុនបង្វិលឬទុនដំណើរការសុទ្ធប្រហែលពី ១៥% ទៅ៤០% នៃចំណាយសរុបប្រចាំឆ្នាំរបស់ខ្លួន ទៅតាមប្រភេទនេសាទនិមួយៗ និងទៅតាមតំបន់និមួយៗផងដែរ (សូមមើលតារាងលេខ២)។

*(នៅមានត)*

ដោយ ទូច ស៊ាងតាណា

43 Tana,T.S., 2001. Dynamic Governance of Cambodian Freshwater Fisheries. Chapter 6. Doctoral Thesis (Aalborg University, Denmark).

## ពន្យល់ពាក្យ

បត់ កិ. : ត្រឡប់តាមទំនង តាមផ្លូវដដែលមកវិញ ត្រឡប់ប្រសព្វមុខ : បត់សំពត់ បត់ស្លឹក បត់ក្រដាស បត់តាមផ្លូវដើមមកវិញ។ បត់បែន កិ. ធ្វើឲ្យបត់ពង់ពេន ; បត់ជើង កិ. ដោះទុក្ខសត្វ។ គុ. ដែលបត់ពង់ពេន ដែលរៀចពេនព័ទ្ធជាល្បត់ : ផ្លូវបត់បែន។ បថ ន. : ផ្លូវ ; ជលបថ (ផ្លូវទឹក)

បទ ន. (សំ.បា.) : ឧបាយ រឿង ហេតុ ទី ការរក្សា ចំណែក ជើង ស្នាម ជើង ផ្លូវ ទំនង ដំណើរ ទំនង ដើមទង។

បទ និ. : ដ្បិត ប្រពន្ធឃើញឃាត់ទៅ ប្តីមិនត្រូវថាកុំអ្នក ឯងខឹងលោ វាយធាក់ ដោយចិត្តធំបទបានស្រា (ច្បាប់ប្រុស បណ្ឌិតមៃ)

បទ ន. : លំនាំនៃសំលេងដែលសូត្រឬដែលច្រៀង។

* បទកាព្យខ្មែរមានប្រមាណ៤៨បទ៖

| | |
|---|---|
| ១. បទ ក ខ | ២.បទកង្កែបលោតកណ្តាលស្រះ |
| ៣. បទកង្កែបលោតស្លាក់ពេជ្រ | ៤. បទកាកគតិ |
| ៥. បទក្របចក្រវាឡ | ៦. បទគោព័ទ្ធស្ទឹង |
| ៧. បទធំត្របីជាន់ | ៨. បទសិង្ហតោលេងកន្ទុយ |
| ៩. បទត្រឡាចឡើងទ្រើង | ១០. បទត្រីពិធព័ន្ធ |
| ១១. បទថយក្រោយ | ១២. បទនមោ |
| ១៣. បទនាគកៀវក្រវាត់ | ១៤. បទនាគបរិព័ទ្ធ |
| ១៥. បទនាគរាជប្លែងឫទ្ធិ | ១៦. បទបន្ទោលកាក |
| ១៧. បទផ្កាឈូករីក | ១៨. បទជាប់ទង |
| ១៩. បទពាក្យ៤ | ២០. បទពាក្យ៦ |
| ២១. បទពាក្យ៧ | ២២. បទពាក្យ៨ |
| ២៣. បទពាក្យ៩ | ២៤. បទពាក្យ១០ |
| ២៥. បទពាក្យ១១ | ២៦. បទពំនោល |
| ២៧. បទភុជង្គលីលា | ២៨. បទព្រហ្មគីតិ |
| ២៩. បទរលកខ្ទប់ច្រាំង | ៣០. បទសារថីទាញរថ |
| ៣១. បទអក្សរសង្វាស | ៣២. បទរមាំងជើងព្រៃ |
| ៣៣. បទរលកយោលយាវ | ៣៤. បទសឡាបសលូន |
| ៣៥. បទព្រះច័ន្ទ្របាំងឆ័ត្រ | ៣៦. បទកង្កែលោតលើគោក |
| ៣៧. បទវង្សវិចិត្រ | ៣៨. បទសហាវ |
| ៣៩. បទសុក្រទិនវិលាស | ៤០. បទសោរទិនវិលាស |
| ៤១. បទកង្កែបលោតផ្ទាត់ខ្ទៅ | ៤២. បទសបាត់សបឹង |
| ៤៣. បទពស់លេបកន្ទុយ | ៤៤. បទសរភញ្ញ |
| ៤៥. បទមករខ្វាក់កែវ | ៤៦. បទយតិភង្គ |
| ៤៧. បទអក្សរលូន | ៤៨. បទមហាជ័យ |

* **បទភ្លេងបុរាណក្នុងរឿងរាមកេរ្តិ៍៖**

| | | |
|---|---|---|
| ១. បទក្រាវណេត | ២. បទច្រំតែង | ៣. បទច្រេះ |
| ៤. បទច្រេះដុក | ៥. បទច្រេះរាម | ៦. បទច្រេះហើយច្រំតែង |
| ៧. បទជន្មា | ៨. បទជើត | ៩.បទជើតច្រំតែង |
| ១០. បទជើតឈិង | ១១. បទជើតស្តេចចេញ | ១២. បទជើតហើយច្រេះ |
| ១៣. បទដំណេក | ១៤. បទថាប្រៀនប្រាក្រាប | ១៥. បទថាពែនហើយពាតដែក |
| ១៦. បទបណក្ខ | ១៧. បទពាក់ដែក | ១៨.បទព្រះលក្សណ៍វាន់មាលា |
| ១៩. បទល្បងកាន់រួចជំហានធំ | ២០. បទសម្តេច | ២១. បទសម្តេចភាណ |
| ២២. បទសម្តេចលា | ២៣. បទសម្តេចលេលា | ២៤. បទសំភារ |
| ២៥. បទសំណា | ២៦. បទសំណាខម | ២៧. បទសំណាខរ |
| ២៨. បទសំណាខ្មែរ | ២៩. បទសំណាលា | ៣០. បទសំណាសៀម |
| ៣១. បទសំណាសៀមសុទ្ធ | ៣២. បទបនណកឱត | ៣៣. បទបំរើ |
| ៣៤. បទបំរើហើយសំណា | ៣៥. បទបំរើហើយសំរាង | ៣៦. បទប្រគំ |
| ៣៧. បទសំណាស្តេចលេលា | ៣៨. បទសំរើប | ៣៩. បទឱត |
| ៤០. បទឱតសៀម | | |

* **បទភ្លេងមហោរីខ្មែរ៖**

| | | |
|---|---|---|
| ១. បទកុលាបរោយ | ២. បទក្រសាំងទាប | ៣. បទខ្មែរច្រូតស្រូវ |
| ៤. បទខ្មែរតម្បាញ | ៥. បទខ្មែរបុកស្រូវ | ៦. បទខ្មែរបំពេកូន |
| ៧. បទខ្មែរយោលទោង | ៨. បទខ្មែរឡើងព្រះពន្លា | ៩. បទចិនឈរមុខទូក |
| ១០. បទចៅព្រាហ្មណ៍ | ១១. បទឆៀងម៉ៃ | ១២. បទផ្កាដើរទេស |
| ១៣. បទផ្កាសំបុរជ្រេះ | ១៤. បទដំណើរខ្មែរ | ១៥. បទនារីជាជួរ |
| ១៦. បទនារីលង្វែក | ១៧. បទបាត់ដំបង | ១៨. បទពេជ្រតូច |
| ១៩. បទភូមាហ៊ោ | ២០. បទរបាំឆ្មា | ២១. បទរបាំផ្លិត |
| ២២. បទរបាំមាន់ | ២៣. បទលាវឡើងប្រាំង | ២៤. បទវាចាផ្អែម |
| ២៥. បទសត្វក្ងោកមាស | ២៦. បទសត្វមហោរី | ២៧. បទសន្ទឹកផ្គរគ្រាំ |
| ២៨. បទសយភ្លេង | ២៩. បទដំរីលេងភ្លុក | ៣០. បទត្រពាំងពាយ |
| ៣១. បទត្រយ៉ងយំថ្ងូរ | ៣២. បទទេព្ភាផ្ទឹ | ៣៣. បទទេពមនោរម្យ |
| ៣៤. បទទេវស្ង័ | ៣៥. បទទោចយំ | ៣៦. បទសារិកា |
| ៣៧. បទសីតាយំថ្លែង | ៣៨. បទស្រលាញ់ផុតចិត្ត | ៣៩. បទស្រីលាវតូច |
| ៤០. បទអណ្តើកស៊ីត្រកួន ... | | |

(ចង់ជ្រាបច្បាស់សូមអានសួនកំណាព្យរបស់ស្មេរដដែល)

---

# ស្វែងយល់អំពីពាក្យ សុភាសិត ( Proverbes )

សុភាសិតជាផ្នែកមួយនៃពាក្យចួនប្រជាប្រិយ។អ្វីៗដែលមានលក្ខណៈប្រជាប្រិយត្រូវតែមានលក្ខណៈបួនយ៉ាង ដូចខាងក្រោមនេះ៖

ក. ប្រធានបទ (sujet): សុភាសិតគឺជាបទពិសោធពីធម្មជាតិ អាកាសធាតុ ផលិតកម្ម ជីវភាពសង្គម សីលធម៌ និងសុជីវធម៌។ បទពិសោធទាំងនោះត្រូវបានគេចាត់ទុកថា ជាបទពិសោធប្រវត្តិសាស្ត្ររបស់ប្រជាជន។

ខ. សិល្បវិធី (stylistique): សុភាសិតមានរចនាសម្ព័ន្ធជាទូទៅពីរផ្នែក (អាចជួនកាលបីឬបួនផ្នែក)។ រវាងផ្នែកទាំងពីរមានអ័ក្ស (axe) មួយនៅកណ្តាល ហើយផ្នែកទីមួយមានចង្វាក់និងចួនគ្នាទៅនឹងផ្នែកទីពីរ។ ផ្នែកទាំងពីរជាគូគ្នានិងសមមូល។ រូបារម្មណ៍ត្រូវរំលេចចេញជារចនាសម្ព័ន្ធតាមឧបមានរូបារម្មណ៍។

គ. មុខងារ (fonction): សុភាសិតមានមុខងារច្រើនយ៉ាង៖

- ជាមធ្យោបាយសម្រាប់សំយោគបទពិសោធជីវិត បទពិសោធ ប្រវត្តិសាស្ត្រប្រជាជន។
- ជាមធ្យោបាយផ្សព្វផ្សាយបទពិសោធពីជំនាន់មួយទៅជំនាន់មួយទៀត (សុភាសិតឆ្លុះបញ្ចាំងមនសិការប្រពៃណី ដូច្នេះវាមានចរិតអភិរក្ស)។ ហេតុនេះហើយសុភាសិតភាគច្រើនហួសសម័យនិងអន់ថយ។
- ជាចន្ទល់សម្រាប់សក្ខីកម្ម។ គេចាត់ទុកសុភាសិតជាឧបធារណ៍(Postulat)គ្មានការជជែកវែកញែកជាសច្ចធម៌ ជាច្បាប់សម្រាប់រៀនដើម្បីយកប្រៀបលើគូសន្ទនា។សុភាសិតត្រូវបានគេប្រើប្រាស់ក្នុងការពិភាក្សាក្នុងសិក្ខាសាលា ប្រដូចទៅនឹងសិស្សដែលប្រើប្រាស់ទ្រឹស្តីបទក្នុងគណិតវិទ្យា។
- ជាមធ្យោបាយអប់រំមនុស្សឲ្យចេះប្រើភាសាខ្លីៗ ប៉ុន្តែមានខ្លឹមសារ សំបូរបែប។ វាបង្រៀនកវីអ្នកនិពន្ធឲ្យចេះរឹតបន្តឹងពាក្យ ដូចជាក្តាប់ដៃអញ្ចឹង។

ឃ.បែបបទសម្តែង (Mode de représentation): សុភាសិតកើតមានតែនៅក្នុងការនិយាយស្តីប្រចាំថ្ងៃរបស់ប្រជាជន។ គេមិនច្រៀងទេ គេទាញហេតុផលពីសុភាសិត។ កាលណានិយាយជាមួយចាស់ៗ បម្រើបម្រាស់សុភាសិតមានច្រើនបំផុត។ ប្រសិនបើគេពុំយល់ពីន័យរបស់សុភាសិត គេពុំអាចយល់ពីគំនិតចាស់ៗឡើយ។ ដូច្នេះបើជាសុភាសិតគេសម្រាប់ទាយហេតុផល វាត្រូវបានប្រើប្រាស់ដូចជាគុណកថា(Citation)។ សុភាសិតខ្មែរគឺជាគតិបណ្ឌិតប្រជាប្រិយរបស់មនុស្សខ្មែរ។វារស់នៅនិងផ្សព្វផ្សាយក្នុងសម្តីខ្មែរដែរគេចាត់ទុកដូចជារុក្ខជាតិដែលដុះលើដីស្រែចម្ការខ្មែរនៅសម័យមុន ហើយដែលបានថែរក្សាទុកលក្ខណៈប្រពៃណីជាតិយ៉ាងច្បាស់លាស់។ សុភាសិតខ្មែរមានប្រភពចេញពី៖

១. ជីវភាពប្រជាជន (Vie du people)

២. ប្រភេទផ្សេងៗនៃនិទានកថាប្រជាប្រិយ (Divers genres du conte populaire)

៣. អក្សរសិល្ប៍សំណេរ (Litte´rature e´crite) ក្នុងចំណោមប្រភពទាំងបីនេះ ប្រភពទីមួយមានសារៈសំខាន់ជាងគេបង្អស់។លក្ខណៈពិសេសនៃសុភាសិតខ្មែរគឺភាគច្រើននៃសុភាសិតទាំងនោះបានឆ្លុះបញ្ចាំងឲ្យឃើញពីជីវភាពកសិករខ្មែរ ក្រោមរបបសក្តិភូមិអាណានិគមនិយម។

ង. នានាភាពនៃសុភាសិតខ្មែរ: (Les varie´te´s des proverbes Khmers)

ង១. សុភាសិតបកស្រាយពីការលោភលន់ ទ្រព្យសម្បត្តិ អំណាចរបស់ពួកអ្នកធំ៖

- យក្សនឹងសាច់ ស្តេចនឹងរាជ្យ។
- ទឹកជន់ បុណ្យស្តេច។
- ជាន់ក ដកស្លាប។
- ទន្លេដប់ មិនស្កប់ សមុទ្រមួយ។
- ទូកតូចកុំប្រដូច ទៅនឹងទូកថ្ងៃ។
- ជន្លេនមិនដែលខ្ជើមដី មន្ត្រីមិនដែលខ្ជើមប្រាក់។

- អ្នកមានទិញសាច់ឲ្យឆ្កែ អ្នកស្រែឆីតែប្រហុក។
- ថយយស ព្រោះប្រមាទ។
- មានប្រាក់អាចប្រើ ខ្មោចឲ្យកិនស្រូវ។

ង២. សុភាសិតបកស្រាយពីការបះបោរផ្លូវចិត្តរបស់ប្រជាជនៈ

- ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី។
- ឃ្លោកលិចអំបែងអណ្តែត។
- ឈ្មុះមុខខ្លាញ់ ចាញ់មុខសេះ។
- ស្រាស់របង មុនក្របីបាត់។
- ពាក់ស្បែកចចកគម្រាមខ្លា។
- ផ្លែចេះតែព្រុស មនុស្សចេះតែដើរ។
- មាន់ណាខ្ពត មាន់នោះពង។
- រេចលើរេចក្រោម ដូចជាត្បាល់កិន។
- ភ្នំខ្ពស់គង់ទាបជាងស្មៅ។
- ឃើញដំរីជុះ កុំជុះតាមដំរី។
- ប្រាជ្ញមិនស្មើប្រប បម្រើស្លឹកត្រចៀកខ្លប មិនស្មើអាឡេមឡឺម។
- គួររូបខ្លាបង្អើលគោ។
- អាករមាន់គម្រាមស្វា។
- អ្នកមានកុំអាលអរ អ្នកក្រកុំអាលភ័យ។
- គេមានកុំអាលអរ គេក្រកុំអាលសើច។
- មានមិនដែលបីត ក្រមិនដែលបីជាន់។
- កុំឃើញខ្លាក្រាបថាខ្លាសំពះ។
- កើតមកមួយជាតិ ធាតុតែមួយចាន។
- អាវុធស្តេចគឺទ្រង់ស្រដី អាវុធសេដ្ឋីគឺមាសប្រាក់ អាវុធទាសករគឺកម្លាំង។

ង៣. សុភាសិតបកស្រាយពីសាមគ្គីភាពផ្ទៃក្នុង រវាងប្រជាជននិងប្រជាជនៈ

- អំពៅមួយបាច់កាច់មិនបាក់ឡើយ។
- សម្តីញុះញង់ នាំបង់សាមគ្គី។
- សូវស្លាប់ខ្លួនចុះ កុំឲ្យស្លាប់ជាតិ។
- ខាំមាត់ សង្កត់ចិត្ត។
- ដឹងគ្នានៅគ្រាក្រ សំបុរល្អនៅខែកត្តិក។
- បើមិនជួយចូកជួយចែវ កុំយកជើងទៅរាទឹក។
- គ្រាន់តែគួរមុខ គំហុកទៅជល់គ្នា។
- អត់ធ្មត់ អត់អោន។
- សូវស្អុចកុំឲ្យដាច់។

ង៤. សុភាសិតបកស្រាយពីការព្យាយាម ការប្រុងប្រយ័ត្ន និងការងារៈ

- តក់ៗពេញបំពង់ ឆុងៗលុងយៃត។
- សឹមៗកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា។
- ប្រញាប់ដេកផ្លូវ សូវៗដល់ផ្ទះ។
- តម្រិះជិះកងង។
- ដំរីជើងបួន នៅគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់ នៅគង់មានភ្លេច។
- ត្រីឆ្តោស៊ីកូនឯង។
- កាប់បំពង់ រង់ទឹកភ្លៀង។
- គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោចអន្សមឆៅ។
- ប្រហែសបាត់ ប្រយ័ត្នគង់។
- លើកដាក់តាមកម្លាំង។
- សូវស្លាប់បាកុំឲ្យស្លាប់មេ សូវលង់ទូកកណ្តាលទន្លេ កុំឲ្យតែភ្លើងឆេះផ្ទះ។

ង៥. សុភាសិតបកស្រាយពីកសិកម្មៈ

- ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ។
- ធ្វើស្រែមើលស្មៅ ទុកដាក់កូនចៅ មើលផៅសន្តាន។
- កុំដាំស្រូវនៅផ្លូវដំរី។
- កុំបាចអង្កាមបញ្ច្រាសខ្យល់។
- សំណាបយោងដី ស្រីយោងប្រុស។
- ធ្វើស្រែទាន់ក្តៅដី ចង់ស្រីទាន់ក្តៅចិត្ត។
- ធ្វើស្រែមិនបាច់ខំភ្ជួរ រក្សាតែម្ជួរស៊ីមិនអស់។
- ធ្វើស្រែខុសមួយឆ្នាំ ឆ្នាំក្រោយគង់ចំណេញ។
- ធ្វើស្រែលើទួល សាកសួរទំនួល។
- ធ្វើស្រែទាន់មានភ្លៀង ស្រែកច្រៀងទាន់ចិត្តចង់។

- ធ្វើស្រែយកស្រូវ គាបអំពៅយកស្ករ។ - មានប្រឡាយ ទើបទឹកហូរ។
- ទឹកតែងហូរ ទៅទីទាប។

ង៦. សុភាសិតបកស្រាយពីការសិក្សាអប់រំ៖

- ចេះដប់ មិនស្មើ ប្រសប់មួយ។ - ចេះឯង ឲ្យក្រែង ចេះគេ។
- ចំណេះចេះតែក្នុងក្បួន ជួនជាត្រូវការរអាចិត្ត។
- គ្រូកាច សិស្សខូច។ - ជាងមិនកើត បន្ទោសដែក។
- មានកង្វេរទើបដំរីខ្លាច មានប្រាជ្ញទើបស្រុកថ្កើង។
- បើស្លឲ្យសាប អង្គុយឲ្យទាប មារយាទឲ្យខ្ពស់។
- លួចគេធ្លាប់ដៃ ដេកថ្ងៃធ្លាប់ភ្នែក។
- ធ្វើទានធ្វើដោយស្មោះ កុំអាឡោះអាល័យខ្លួន។
- ត្រីមួយត្រក តែស្អុយមួយ ស្អុយទាំងអស់។ - សងសឹកជាការកម្លៅ។
- ដើយស្កកឱនដាក់ក្រាប់។ - ចេះស្ទើរ ធ្វើភ្លើ ល្អជាង។
- បើមិនទាន់ជាក់ កុំអាលញាក់ចិញ្ចើម។ - ចេះពីរៀន មានពីរក។
- បំណាច់នឹងចេះ ឲ្យគេកោត បំណាច់នឹងឆោត ឲ្យគេអាណិត បំណាច់នឹងហ៊ាន ឲ្យមានចិត្ត បំណាច់នឹងគិត ឲ្យបានការ បំណាច់នឹងថា ឲ្យមានខ្នាត។
- កុំនិយាយស្តី បាតដៃខ្នងដៃ។ - ផ្តិប៉ុឲ្យក្របីស្តាប់។
- ស៊ីច្រើនៗជុះ លេងច្រើនៗឈ្លោះ ដេកច្រើនៗខ្ជិល។
- ធូន់នៅថ្ម ក្រនៅក្តី។ - ធ្វើការតិច ចំណាយច្រើន ចម្រើនក្រ។
- កោកៗសឹកមាត់ត្រដោក ឆ្អែតតែពោះក្របី។ - រពិសដៃផ្ទៃឆ្អែត។

ង៧. សុភាសិតបកស្រាយពីកង្វះលំនឹងក្នុងអាជីវកម្ម៖

- ចាក់អង្ករ យកអង្កាម។ - ទំពក់វារទៅ ទើបញ្ចៅវារមក។
- ចាប់នេះចាប់នោះ មិនឆ្លោះត្រង់ណា។ - ប្រាក់ក៏បង់ ចង់ក៏ដាច។
- អស់ម្ទុលមួយបាវ អារមិនទាន់ឡើងខ្លួន។ - យកសំណាញ់បង់ខ្យល់។
- លិចកញ្ចង់លង់កញ្ជើ។ - ត្រីរស់ក៏រួច ទន្សាយក៏រួច។
- ចាប់ច្រវា សម្លឹងជ្រោយ។
- ចង់បុណ្យបានបាប ចចើងចង់លាភ រែងបាត់ធនទៅ។
- ចាបមួយនៅដៃប្រសើរក្រៃ ជាងចាបម្ភៃលើចុងឈើ។
-ចាប់វល្លិមួយ រញ្ជួយរាល់ដើម។ - ចាយវាយក្រៅតម្រា នូវវិនាសធនផង។
- ស្មៀមជាងស្រដី ទំពារចេកខ្ចី ជាងមាត់ទំនេរ។

ង៨. សុភាសិតបកស្រាយពីសកម្មភាពផ្សេងៗក្នុងសង្គម៖

- ឬកឆ្មើងឆ្មៃ ចង្រៃខ្លួន។ - រៀចធ្វើកង់ ត្រង់ធ្វើដង។
- ងប់នឹងល្បែង តែងវិនាស។
- ឈើកោងវល្លិ៍ពាត់ មនុស្សសាត់ព្រាត់ កុំយកខ្លួនបៀត។
- មានៈនឹងល្បែង តែងអន្តរាយ។ - ខឹងនឹងគោ វាយរទេះ។
- កុំទុំមុនស្រគាល។ - សម្តីត្រង់ ទាស់ត្រចៀក។
- ពាក្យពិត រែងស្លែង។ - ស្លឹកឈើជ្រុះមិនឆ្ងាយពីគល់។
- ពេលឈឺយកដំរីទៅបន់ ដល់ពេលស្រន់ពងមាន់មួយស្តាយ។

- គោមួយក៏យប់ គោដប់ក៏ល្ងាច។
- កុំរងមុខដឹង កុំទទឹងមុខសឹក។
- ចូលព្រៃទាន់ព្រឹក ចង់សឹកទាន់ក្មេង។
- អូសសម្រាស់ ប្រទះពាក្យ។
- រស់តែមាត់ត្រគៀកងាប់ស្អុក។
- យល់ញាតិ ឃ្លាតច្បាប់។
- ម្នោៗយកជ័រញ្ចោតៀ្យតឃ្លៀក។
- មាន់ពងលើស្រូវជង្រុក។
- មើលស្មា សឹមរែក។
- ពុតផ្សែង ជាដុំ។
- ផោមក្នុងទឹកគង់ស្អុយ។
- អង្គុយលើចង្អេរលើកខ្លួនឯង។
- ត្រឡាចគង់មានបណ្ដូល មនុស្សទាំងមូលគង់មានចិត្ត។
- ចេះកប់ពពក ជ្រកអាចម៍ជន្លេន។
- ខ្វះមួយចំអាមដល់មេឃ។
- ជើងមិនជាប់ដី ក្បាលមិនទល់មេឃ។
- ថ្លោះយសព្រោះព្រហើន។
- សង់ផ្ទះតាមចិត្តអ្នកនៅ។
- ល្អល្អះតែមាឌ មារយាទមិនបាន។
- លោភពេកវាបែកពោះ។
- លើកស្នារំអាក្អែក។
- ចុះទឹកក្រពើ ឡើងលើខ្លា។
- គោលឿនសឹកក ស្រីល្អសឹកគូថ។
- កូនអ្នកក្រធ្វើទាហាន កូនអ្នកមានធ្វើនគរបាល កូនកម្មាភិបាលទៅបរទេស។

ង៩. សុភាសិតបកស្រាយពីការចំអកឲ្យរបបខ្មែរក្រហមៈ

- ធ្វើស្រែពឹងមេឃស៊ីបាយ ធ្វើស្រែពឹងប្រឡាយស៊ីបបរ។
- មហាលោតផ្លោះ មហាបដិវត្តន៍ កំទេចវត្ត ធ្វើទ្រុងជ្រូក។
- មហាលោតផ្លោះ មហាអស្ចារ្យ រុះសាលា ធ្វើជង្រុកស្រូវ។
- មហាលោតផ្លោះ មហារុងរឿង រុះផ្ទះក្បឿង ធ្វើផ្ទះស្បូវ។
- មហាលោតផ្លោះ មហាត្រឹមត្រូវ រុះផ្ទះស្បូវ ធ្វើទ្រើងឃ្លោក។
- ខោអាវខ្មៅហោប៉ៅក្ដោង ដំណើរកោងរាងលោតៗ ផុតពីគេចំកោងអួត អញកំទេចបានគ្រាន់ដែរ។
- ព្រឹកមួយកំបោយ ល្ងាចមួយកំបោយ អង្គការវាល់ឲ្យ  កៀសហើយកាយចេញ។
- ត្រកួនកុមារ ខាត់ណាស្ត្រី ស្ពៃបុរស ប៉េងប៉ោះនារី ផ្ទីយុវជន ស្ពន់យាយតា ឆារួមឆារួម។
- កូនអើយទំរាំបានដូចសព្វថ្ងៃ កូនរំដោះដីយកឲ្យឪរែក។
- កសាងដូចជាកសេះ   កទាល់តម្រិះកដប។

ង១០. សុភាសិតបកស្រាយពីការគំរាមបំបាក់ស្មារតីប្រជាជនរបស់អង្គការខ្មែរក្រហមៈ

- សក់អ្នកណា ក្បាលអ្នកហ្នឹង។
- អង្គការអារក។
- អង្គការភ្នែកម្នាស់។
- កង់ប្រវត្តិសាស្ត្រវិល លូកដៃដាច់ដៃ លូកជើងដាច់ជើង។
- ទុកក៏មិនចំណេញ ដកចេញក៏មិនខាត។
- គ្រុនញាក់គ្រុនញ័រ គ្រុនគ្រាក់ទ័រគ្រុនឡាន គ្រុនស៊ីបាយបាន គ្រុនសតិអារម្មណ៍។
- ជីកស្មៅជីកទាំងឫស។

## ឱ ដួងច័ន្ទ ! ( បទពាក្យ៩ )

រាត្រីនេះដួងច័ន្ទ្រាមូលក្រឡង់
បង្ហាញអង្គភក្ត្រពណ្ណរាយចាកបូព៌ា
ញញឹមព្រាងមើលលោកាពីមេឃា
ប្រាកដជាពេញបូណ៌មីរង្សីសាយ។
មេឃស្រឡះចាកពពកមន្ទិលហ្មង
តារាផងក៏ភ្លឺផ្លេកចាំងពីឆ្ងាយ
ឯផែនដីមនុស្សប្រុសស្រីតុបតែងកាយ
ដើរសប្បាយកំសាន្តដោយក្រុងសម័យ។
ព្រះច័ន្ទភ្លឺបំភ្លឺលោកមកយ៉ាងនេះ
ភ្លឺដូច្នេះពាន់ម៉ឺនឆ្នាំជានិស្ស័យ
មនុស្សច្រើនតយល់លម្អតតឧបមេយ្យ
ចិត្តអាល័យគួចស្រឡាញ់ដួងចន្ទ្រា។
តែយប់នេះសម័យនេះសតវត្សនេះ
មនុស្សប្លែកម្លេះមិនដូចមនុស្សជាន់ដូនតា
ដើរត្រសងក្រោមដួងច័ន្ទដ៏ភ្លឺថ្លា
ប៉ុន្តែចិត្តគ្មានចេតនាដួងច័ន្ទថ្លៃ។
គេដើរទៅគេទៅមើលខុនស៊ីតល្បែង
ល្បាំសម្តែងសំដិលសាច់យកកម្រៃ
គេទៅមើលពិពណ៌អួតយកថ្មីដៃ
គេពុំមានឲ្យតម្លៃដួងចន្ទឡើយ។

## អ្នកប្រុស ( បទពាក្យ៧ )

លេងខ្លួនលឿនលូតតាមម៉ូតក្រោយ
ធ្វើឫកវាងឲ្យឃើញហ៊ឺហា
ស្គាល់គ្រប់កន្លែងល្បែងបនបារ
ឡានសោតម៉ាកណាថ្លៃចម្លែក។
លើគ្រែបានភ្លក់រសជាតិស្រី
គ្រប់ធុនគ្រប់វ័យសម្បុរស្បែក
លុយកាក់រាប់ភ្លេចចាយជាសែក
ហាក់លោតរាំរែកស៊ីហួសឃ្លាន។
ដីផ្ទះវីឡាគ្រប់កន្លែង
បុរីផ្ទះល្វែងថៃមវិមាន
ប្រាក់កាសសេសសល់វាល់រយលាន
បង្វែរធនធានទៅបរទេស។
បែបហ្នឹងទើបហៅអ្នកចេះរស់
ពេញដោយកិត្តិយសសម័យនេះ
ចាត់ជាអ្នកឆ្លាតដោយតម្រិះ
ធុននេះទើបហៅថាអ្នកប្រុស។

## រឿងសត្វរើសគ្នាធ្វើជាស្តេច

ក្នុងគ្រាកន្លងរំលងដ៏យូរលង់ណាស់មកហើយ មនុស្សទាំងអស់នៅលើផែនដីលើពិភពលោកនេះ ពុំទាន់មាននរណាមួយជាធំសម្រាប់ត្រួតត្រាគ្នានៅឡើយ។ លុះចំណេរកាលមកខាងក្រោយ ទើបគេជំនុំគ្នាលើកមនុស្សម្នាក់ជាស្តេច ដើម្បីឲ្យសោយរាជ្យសម្បត្តិ និងគ្រប់គ្រងអាណាប្រជានុរាស្ត្រតទៅ។ ពពួកសត្វទាំងឡាយគឺ ៖ ម្រឹគ បក្សី និងមច្ឆា កាលបើបានឃើញមនុស្សមានស្តេចមួយអង្គសម្រាប់ត្រួតត្រាប្រជាពលរដ្ឋទូទៅដូច្នោះ ក៏នាំគ្នាផ្អើលឆោឡោជ្រួលច្របល់ប្រកូកប្រកាសឲ្យពិភពលោក គឺមនុស្សនិងសត្វទាំងអស់ដឹងថា ពពួកខ្លួននេះពុំទាន់មានស្តេចត្រួតត្រានៅឡើយទេ ដើម្បីឲ្យពិភពលោកជួយគិតគូរអំពីពពួកខ្លួននេះផង។ មិនយូរប៉ុន្មានមនុស្សទាំងអស់ក៏នាំគ្នាជួយគិតគូររើសស្តេចឲ្យពពួកសត្វទាំងនោះ។ គេបានតាំងសត្វតោ(រាជសីហ៍)ដែលជាសត្វខ្លាំងពូកែមានឥទ្ធិឫទ្ធីអង់អាចមានប្រាជ្ញាឈ្លាសវៃ និងមានចរិយាស្រគត់ស្រគំជាងគេឲ្យធ្វើជាស្តេចនៃសត្វម្រឹគ។ ពពួកសត្វម្រឹគទាំងឡាយពេញចិត្តនឹងស្តេចរបស់ខ្លួននេះដោយឥតមានប្រកែកអ្វីឡើយ។ ពពួកសត្វត្រី គេបានតាំងមច្ឆានុដែលជាត្រីធំជាងគេ ឲ្យធ្វើជាស្តេចនៃមច្ឆជាតិទាំងអស់ ពពួកសត្វមច្ឆាក៏ទទួលយកដោយពេញចិត្តយ៉ាងក្រៃលែង។

ឯពពួកបក្សី លុះបានមកជំនុំរើសរកសត្វដែលនឹងឲ្យធ្វើជាស្តេចនៃបក្សីទាំងពួង ស្រាប់តែមានបេក្ខជនពីររូបឈរឈ្មោះឲ្យគេតាំង គឺសត្វក្អែកមួយ សត្វមៀមមួយ។ សត្វទាំងពីរនេះសុទ្ធតែមានសត្វជាបរិពារយ៉ាងច្រើនរៀងៗខ្លួន។ សត្វទាំងពីរនេះមានគំនិតចង់ធ្វើជាស្តេចគ្រប់ៗគ្នា ម្ល៉ោះហើយក៏បែកជាពួកបក្សដើរឃោសនាប្រកួតប្រជែងអួតតែបក្សពួករបស់ខ្លួនរៀងៗខ្លួន មិនតែប៉ុណ្ណោះ ថែមទាំងដើរឃោសនាបន្តុះបង្អាប់គ្នាទៅវិញទៅមកផង ខាងក្អែកថា៖ «នរណានឹងឲ្យសត្វមៀមធ្វើជាស្តេចកើត! បើភ្នែកវាធំៗម្ល៉េះ។ តែកាលណាវាបានធ្វើជាស្តេចលើបក្សីផងទាំងពួង វានឹងបំផ្លិចបំផ្លាញអស់បក្សីផងនានា បើអ្នកទាំងអស់គ្នាមិនជឿខ្ញុំត្រូវអ្នកមើលតែភ្នែកវា យើងគង់យល់បានថាវាជាសត្វកាចយង់ឃ្នងប្រាកដមែន»។ ឯពពួកសត្វមៀមក៏ឃោសនាបង្អាប់ទៅសត្វក្អែកវិញថា «យើ! អាសត្វក្អែកខ្មៅទាំងឆ្អឹង! អាឯងនេះជាសត្វខ្មៅមិនមែនខ្មៅតែរោមស្លាបនិងសាច់តែប៉ុណ្ណោះទេ ខ្មៅរហូតទៅដល់ចិត្តគំនិតទៀត បើនរណាសុខចិត្តតាំងអាសត្វក្អែកឲ្យធ្វើជាស្តេច ក្អែកវានឹងជិះជាន់សង្កត់ សង្កិនលើសត្វនានាជាមិនខាន ព្រោះអានេះចិត្តខ្មៅណាស់ វាជាសត្វធ្លាប់រកស៊ីតែលួចឆក់របស់គេជាអាហារ បើវាបានធ្វើស្តេចវានឹងលែងលួចឆក់ហើយវាទៅសង្កត់កគេយកស៊ីទាំងភ្នែកស្រស់តែម្តង។ អ្នកទាំងអស់គ្នាមិនបាច់គិតវែងឆ្ងាយទេ មើលតែរបរវារកស៊ីសព្វថ្ងៃនិងចរិយាក្រឡេមក្រឡឹមហើយនិងសម្បុរស្បែកវាក៏គង់ដឹងហើយ»។

បេក្ខជន ក្អែក និង មៀម ឃោសនាប្រឆាំងគ្នាយ៉ាងនេះរហូតទាល់តែបែកជាបក្សពួកយ៉ាងធំកើតជាជម្លោះប្រកែកគ្នាយ៉ាងខ្លាំង ទើបពពួកសត្វទាំងអស់ដែលមិនចូលដៃចូលជើងខាងបក្សណា ក៏ជំនុំគ្នាតាំងសត្វហង្សឲ្យធ្វើជាស្តេចនៃសត្វបក្សីទាំងអស់រហូតមក។ ព្រោះហេតុនេះបានជាក្អែកនិងមៀមចេះតែ ស្អប់គ្នា ដរាបមកដល់សព្វថ្ងៃនេះជាប់ជាទម្លាប់មួយ ដែលចែកសត្វជាពួករកស៊ីពេលយប់ ពួករកស៊ីពេលថ្ងៃ ហើយទាំងពីរពួកនេះឃើញគ្នាមិនបានទេ តែងប្រដេញប្រចឹកប្រខាំគ្នាជាប់ជានិច្ច។



ប្រាសាទព្រះវិហារ



ប្រាសាទបន្ទាយឆ្មារ